# ជំពូកទី ៣
# ក្របខ័ណ្ឌច្បាប់

Draft

Draft

# ជំពូកទី៣

## ក្របខ័ណ្ឌច្បាប់

### ៣.១ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ

១. ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ត្រូវបានអនុម័តដោយរដ្ឋសភាជាតិ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦ និងប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស / រកម / ១២៩៦ / ៣៦ ចុះថ្ងៃ ទី២៤ ខែធ្នូ ឆ្នាំ១៩៩៦។ ច្បាប់នេះមានគោលដៅ:

- ការពារលើកកំពស់គុណភាពបរិស្ថាន និងសុខភាពពលរដ្ឋ ដោយធ្វើការទប់ស្កាត់ការកាត់បន្ថយ និងការត្រួតពិនិត្យការបំពុលបរិស្ថាន។
- វាយតំលៃហេតុប៉ះពាល់បរិស្ថាន មុននឹងចេញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ចំពោះរាល់គំរោង ដែលបានស្នើឡើង។
- ធានាមានការអភិរក្ស អភិវឌ្ឍន៍ ការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផល និងប្រកប ដោយនិរន្តរភាព និងភាពស្ថិតស្ថេរនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា។
- លើកទឹកចិត្ត និងផ្តល់លទ្ធភាពឲ្យសាធារណៈជនចូលរួមក្នុងការពារបរិស្ថាន និងការគ្រប់គ្រង ធនធានធម្មជាតិ។
- បង្រ្កាបអំពើទាំងឡាយណាដែលធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន។

២. ទាក់ទងនឹងការគ្រប់គ្រងនូវធនធានធម្មជាតិ ច្បាប់នេះតំរូវឲ្យបណ្តាក្រុមហ៊ុនទាំងអស់ត្រូវរៀបចំ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ឬរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ពេញលេញ (EIA)។ ផ្អែកលើច្បាប់នេះបានចែងនៅក្នុងមាត្រាទី៦ និងទី៧ នៃជំពូកទី៣ ដូចខាងក្រោម:

Draft

<u>មាត្រា៦៖</u>

- ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុវត្តលើគំរោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតំលៃដោយក្រសួងបរិស្ថានមុនដាក់ជូនរដ្ឋាភិបាលសំរេច។
- ការវាយតំលៃនេះត្រូវអនុវត្តផងដែរ ចំពោះសកម្មភាពដែលមានស្រាប់ និងកំពុងតែមានដំណើរការ ហើយពុំទាន់បានវាយតំលៃហេតុប៉ះពាល់បរិស្ថាននៅឡើយ។
- បែបបទនៃកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើ របស់ក្រសួងបរិស្ថាន។
- ប្រភេទនិងទំហំគំរោង និងសកម្មភាពដែលបានស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់និង កំពុងដំណើរការទាំងឯកជន និងសាធារណៈដែលត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាននេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន។

<u>មាត្រា៧៖</u>

- ចំពោះរាល់ពាក្យសុំធ្វើគំរោងវិនិយោគ និងរាល់គំរោងដែលរដ្ឋស្នើឡើង ត្រូវមានការវាយតំលៃហេតុប៉ះ ពាល់បរិស្ថានដំបូង (IEIA) ឬការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA) ដូចមានចែង ក្នុងមាត្រា៦នៃច្បាប់នេះ។ ក្រសួងបរិស្ថានត្រូវពិនិត្យ និងផ្តល់យោបល់លើ IEIA ឬ EIA ទៅអង្គការ

មានសមត្ថកិច្ច ក្នុងរយៈពេលដូចបានកំណត់ក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

## ៣.២ ច្បាប់ស្តីពីព្រៃឈើ

២. ច្បាប់ស្តីពីព្រៃឈើត្រូវបានអនុម័តដោយរដ្ឋសភាជាតិ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០២ ហើយដែលព្រឹទ្ធសភាបានយល់ព្រមតាមទំរង់ និងគិតនៃច្បាប់ទាំងស្រុងកាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០២ និងប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២។ មាត្រាដែលពាក់ព័ន្ធនឹងការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៃគំរោងវិនិយោគនេះមានដូចខាងក្រោមៈ

<u>មាត្រា១៖</u>

- ច្បាប់នេះកំណត់អំពីក្របខ័ណ្ឌនៃការគ្រប់គ្រង ការប្រមូលផល ការប្រើប្រាស់ ការធ្វើអាជីវកម្ម ការអភិវឌ្ឍន៍ និងការអភិរក្សព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គោលបំណងនៃច្បាប់នេះ គឺជានានូវការគ្រប់គ្រងនៃព្រៃឈើប្រកបដោយនិរន្តរភាពដើម្បីប្រយោជន៍សង្គម-សេដ្ឋកិច្ចនិងបរិស្ថាន រួមទាំងការអភិរក្សជីវៈចំរុះ និងមរតកវប្បធម៌។

<u>មាត្រា៣៖</u>

- ការគ្រប់គ្រងព្រៃឈើត្រូវស្ថិតនៅក្រោមក្នុងដែនសមត្ថកិច្ចទូទៅ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការគ្រប់គ្រងព្រៃលិចទឹកត្រូវស្ថិតនៅក្រោមច្បាប់មួយដោយឡែក។ រដ្ឋផ្តល់សិទ្ធិគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថានក្នុងបទបញ្ញត្តិទាំងឡាយនៃច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធម្មជាតិ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ព្រះរាជក្រឹត្យស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ និងលិខិតបទដ្ឋានច្បាប់ផ្សេងទៀត។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការអនុវត្តន៍ច្បាប់ចំពោះបទល្មើសព្រៃឈើ ដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិ ក្រោមការសម្របសម្រួលជាមួយក្រសួងបរិស្ថាន ស្របតាមបទបញ្ញត្តិដូចមានចែងនៅក្នុងជំពូកទី១៤នៃច្បាប់នេះ។
- សកម្មភាពនេះមិនធ្វើឲ្យប៉ះពាល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចចែងក្នុងច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ។

<u>មាត្រា៤៖</u>

- ក្នុងការអនុវត្តន៍ច្បាប់នេះ រាល់ការសំរេចរបស់រដ្ឋាភិបាល ដែលមានសក្តានុភាពចំពោះហេតុប៉ះពាល់ធ្ងន់ធ្ងរ ទៅលើប្រជាពលរដ្ឋទូទៅលើសហគមន៍មូលដ្ឋាន និងលើធនធានព្រៃឈើនៃ ព្រះរាជាណាចក្រកម្ពុជា ត្រូវមានការចូលរួមជាសាធារណៈ។
- សកម្មភាពចំបងៗ ដែលពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ ដែលអាចបណ្តាលឲ្យមានការប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថានចាំបាច់ត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និង ហេតុប៉ះពាល់សង្គម ដោយផ្អែកលើក្រុមបច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជា និងស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

❖ ឯកសារវាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ត្រូវផ្តល់ជូនសំរាប់ការចូលរួមផ្តល់មតិជាសាធារណៈរាល់ការសំរេចចុងក្រោយលើសកម្មភាពចំបងៗ ពាក់ព័ន្ធទៅនឹងមជ្ឈដ្ឋានព្រៃឈើ រាជរដ្ឋាភិបាល ត្រូវពិចារណាលើអនុសាសន៍ចុងក្រោយនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ ការសំរេចចុងក្រោយណាមួយក្រោមមាត្រានេះ រាជរដ្ឋាភិបាលអាចជូនដំណឹងជាសាធារណៈ។

<u>មាត្រា៣៧៖</u>

❖ សហគមន៍មូលដ្ឋានដែលប្រកបរបរចំការពនេចរមានលក្ខណៈប្រពៃណី អាចអនុវត្តលើដីកម្មសិទ្ធិសហគមន៍ជនជាតិភាគតិចដែលបានចុះបញ្ជីការរួចហើយជាមួយរដ្ឋ។ ផ្នែករដ្ឋបាលព្រៃឈើ នៃមូលដ្ឋាននេះ ត្រូវផ្តល់ការអនុញ្ញាតិ ការគ្រប់គ្រង និងការត្រួតពិនិត្យនៃសកម្មភាពនេះ ដែលជាផ្នែកមួយនៃផែនការគ្រប់គ្រងព្រៃសហគមន៍នោះ។ ការអនុវត្តន៍ចំការពនេចរត្រូវហាមឃាត់ ចំពោះព្រៃធម្មជាតិទាំងឡាយណាដែលមិនទាន់មានការប៉ះពាល់ក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍។ ដីព្រៃឈើដែលរៀបចំសំរាប់ចំការពនេចរ ត្រូវកំណត់ដោយអនុក្រឹត្យ។

<u>មាត្រា៣៩៖</u>

❖ គ្មានរូបវន្តបុគ្គលណាមានសិទ្ធិផ្តល់ការអនុញ្ញាតទោះបីដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ឲ្យកាប់ដើមឈើ ឬធ្វើសកម្មភាពគ្រប់យ៉ាងដើម្បីប្រមូលផល អនុផលព្រៃឈើ ឬកាន់កាប់ដីក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ផ្ទុយនឹងបទបញ្ញត្តិនៃច្បាប់នេះឡើយ។

<u>មាត្រា៩៤៖</u>

❖ បុគ្គលិកណាដែលបានប្រព្រឹត្តបទល្មើសព្រៃឈើ ធ្វើឲ្យប៉ះពាល់ខូចខាតដល់មជ្ឈដ្ឋានព្រៃឈើ ត្រូវចេញថ្លៃស្តារ ឬជួសជុលការខូចខាតមានលក្ខខណ្ឌដូចដើមឡើងវិញ។

**៣.៣ ច្បាប់ភូមិបាល**

៣. ច្បាប់ភូមិបាល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទម្រង់ និងគតិនៃច្បាប់ទាំងស្រុងកាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០១ និងប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១។ ច្បាប់នេះមានគោលដៅ:

<u>មាត្រា៣៖</u>

❖ ជនគ្រប់រូបត្រូវគោរពទ្រព្យសម្បត្តិរបស់រដ្ឋ និងកម្មសិទ្ធិឯកជនស្របច្បាប់ លើអចលនវត្ថុ។ ការគ្រប់គ្រងផ្នែករដ្ឋបាលសុរិយោដីលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ និងការចេញប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុទូទាំងព្រះរាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។ បទបញ្ញា និងនិតិវិធីនៃការគ្រប់គ្រងអចលនវត្ថុដែលជាទ្រព្យសម្បត្តិរដ្ឋ នឹងត្រូវកំណត់ដោយអនុក្រឹត្យ។

<u>មាត្រា២៣៖</u>

- ❖ សហគមន៍ជាតិដើមភាគតិច គឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ សេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទំលាប់នៃការប្រើប្រាស់ជាសមូហភាព។
- ❖ ក្នុងពេលរង់ចាំការកំណត់ខាងផ្លូវច្បាប់ទូវលក្ខន្តិកៈរបស់សហគមន៍ ក្រុមដែលមានជាក់ស្តែងមកទល់បច្ចុប្បន្ននេះ នឹងបន្តគ្រប់គ្រងសហគមន៍ និងអចលនវត្ថុរបស់ខ្លួនតាមប្រពៃណី ហើយត្រូវ អនុវត្តតាមបញ្ញត្តិនៃច្បាប់នេ។

<u>មាត្រា២៤៖</u>

- ❖ ចាត់ទុកជាសមាជិកនៃសហគមន៍ជនជាតិដើមភាគតិចដែលអាចទទួលគុណប្រយោជន៍ពីការធានាសិទ្ធិ និងការការពារដែលរៀបចំឡើងដោយច្បាប់នេះ រាល់បុគ្គលដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យនៃជាតិពន្ធុ អំពីវប្បធម៌ និងសង្គមរបស់សហគមន៍ ដែលទទួលស្គាល់ដោយមតិភាគច្រើននៃសមាជិកដទៃទៀត និងដោយព្រមទទួលនូវសាមគ្គីភាព និងភាពចំណុះដែលនាំឲ្យមានការចូលក្នុងសហគមន៍។

<u>មាត្រា២៥៖</u>

- ❖ ដីសហគមន៍ជនជាតិដើមភាគតិច គឺជាដីទាំងអស់ដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន និងប្រកបរបរកសិកម្មប្រពៃណី។
- ❖ ដីសហគមន៍ជនជាតិដើមភាគតិចមិនមែនមានតែដីដែលបានដាំដុះជាក់ស្តែងនោះទេ ប៉ុន្តែមានដីបំរុងចាំបាច់ក្នុងការផ្លាស់វេនដំណាំថែមទៀត ដែលតម្រូវទៅតាមរបៀបទាញយកផលដែលធ្លាប់ធ្វើកន្លងមក ហើយត្រូវបានទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាល។
- ❖ ការវាស់វែង និងការកំណត់ព្រំប្រទល់នៃអចលនវត្ថុរបស់សហគមន៍ទាំងនោះ ត្រូវកំណត់ទៅតាមស្ថានភាពជាក់ស្តែងដូចដែលបានអះអាងដោយសហគមន៍ ដោយមានការព្រមព្រៀងពីអ្នកជិតខាង និង ដែលបានកំណត់តាមនីតិវិធីក្នុងមាតិកាទី៦ នៃច្បាប់នេះ និងអនុក្រឹត្យពាក់ព័ន្ធ។

<u>មាត្រា២៦៖</u>

- ❖ កម្មសិទ្ធិនៃអចនវត្ថុដែលបានចែងក្នុងមាត្រា២៥ ត្រូវបានផ្តល់ដោយរដ្ឋជូនសហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាព។ កម្មសិទ្ធិសមូហភាពរួមមានរាល់សិទ្ធិ និងការការពារកម្មសិទ្ធិ ដូចកម្មសិទ្ធិឯកជនដែរ។ប៉ុន្តែសហគមន៍នោះ គ្មានសិទ្ធិចាត់ចែងនូវចំណែកណាមួយនៃកម្មសិទ្ធិសមូហភាពដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋឲ្យទៅបុគ្គល ឬក្រុមណាមួយបានឡើយ។
- ❖ ការអនុវត្តន៍នូវសិទ្ធិជាកម្មសិទ្ធិទាក់ទងនឹងអចលនវត្ថុរបស់សហគមន៍ និងលក្ខខណ្ឌជាក់លាក់នៃការប្រើប្រាស់ដីត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរ ប្រពៃណី និងយន្តការនៃការធ្វើសេចក្តីសំរេចរបស់សហគមន៍ អនុលោមតាមទំនៀមទំលាប់របស់ពួកគេ ហើយត្រូវដាក់ឲ្យនៅក្រោមច្បាប់នៃការអនុវត្តន៍ទូទៅទាក់ទងនឹងអចលនវត្ថុដូចជា ច្បាប់ការពារបរិស្ថានជាដើម។

- ❖ បញ្ញត្តិនៃមាត្រានេះ មិនមែនជាឧបសគ្គដល់សកម្មភាពការងាររបស់រដ្ឋ ដែលជាតម្រូវការនៃផលប្រយោជន៍ជាតិ ឬតម្រូវការជាបន្ទាន់របស់ជាតិឡើយ។

<u>មាត្រា២៧៖</u>

- ❖ ដើម្បីសម្រួលដល់ការវិវត្តន៍វប្បធម៌ សេដ្ឋកិច្ច និងសង្គមនៃសមាជិកសហគមន៍ជនជាតិភាគតិច និងដើម្បីអនុញ្ញាតឲ្យពួកគេបានចេញដោយសេរីពីសហគមន៍ ឬរួចផុតពីសហគមន៍ ឬរួចផុតពីការបង្ខិតបង្ខំសិទ្ធិនៃកម្មសិទ្ធិឯកត្តជន អាចនឹងត្រូវផ្ទេរជាពិសេសឲ្យពួកគេបានលើចំណែកសមស្របមួយនៃដីដែលប្រើដោយសហគមន៍ ប៉ុន្តែចំណែកនៃដីដែលជាកម្មវត្ថុនៃការយកធ្វើជាកម្មសិទ្ធិឯកជននោះ មិនអាចជាដី ដែលចូលក្នុងនិយមន័យទូទៅនៃទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទេ។

<u>មាត្រា២៨៖</u>

- ❖ គ្មានអាជ្ញាធរណាមួយក្រៅពីសហគមន៍ អាចទទួលបានសិទ្ធិលើអចលនវត្ថុរបស់ជនជាតិដើមភាគតិចបានឡើយ។

<u>មាត្រា៤៣៖</u>

- ❖ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនអាចជាកម្មវត្ថុនៃលទ្ធកម្មកម្មសិទ្ធិបានឡើយ ទោះជាករណីណាក៏ដោយ។ ស្ថានភាពនៃអ្នកកាន់កាប់ទ្រព្យសម្បត្តិ សាធារណៈរបស់រដ្ឋនៅតែមិនទៀងទាត់ និងខុសច្បាប់ដដែល ប្រសិនជាស្ថានភាពនោះមិនកើតចេញពីការអនុញ្ញាតិតាមបែបផែនដែលបានកំណត់ដោយច្បាប់ទេនោះ។ បុគ្គលកាន់កាប់ខុសច្បាប់ត្រូវបង្ខំចិត្តឲ្យចាកចេញជាបន្ទាន់ ហើយទទួលទណ្ឌកម្មដែលបានកំណត់ក្នុងមាត្រា២៥៩ នៃច្បាប់នេះ។ បុគ្គលកាន់កាប់ខុសច្បាប់ គ្មានសិទ្ធិទាមទារសំណងសំរាប់ចំណាយលើការងារ និងការកែលំអ ដែលខ្លួនបានធ្វើនៅលើអចលនវត្ថុនោះឡើយ។

<u>មាត្រា៥៨៖</u>

- ❖ សម្បទានដី អាចធ្វើឡើងបានតែនៅលើដីដែលជាចំណែកនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ សម្បទានដីមិនអាចប៉ះពាល់ផ្លូវគមនាគមន៍ ដីចំណីផ្លូវ និងដីចាំបាច់សំរាប់ថែទាំ ក៏ដូចជាផ្លូវទឹក ត្រពាំងបឹង និងដែនទឹកបំរុងដែលមានប្រយោជន៍ដល់ការរស់នៅរបស់ប្រជាពលរដ្ឋឡើយ។

## ៣.៤ ច្បាប់ការងារ

៤. ច្បាប់ស្តីពីការងារ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១០ ខែមករា ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៦ និតិកាលទី១ និងប្រកាសឲ្យប្រើនៅព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៩៧។ ច្បាប់នេះមានគោលដៅៈ

### ៣.៤.១ ប្រាក់ឈ្នួល

<u>មាត្រា ១០២៖</u>

- ❖ តាមន័យនៃច្បាប់នេះពាក្យថាប្រាក់ឈ្នួល ទោះបីការកំណត់ ឬរបៀបគិតយ៉ាងណាក៏ដោយ មានន័យថាឈ្នួលការងារ ឬឈ្នួលសេវាដែលអាចគិតជាប្រាក់បាន ឬកំរិតបានដោយការព្រមព្រៀងគ្នា

ឬដោយច្បាប់ជាតិ ហើយដែលនិយោជកត្រូវបើកឲ្យកម្មករនិយោជិតតាមកិច្ចសន្យាជួលការងារ ឬសេវាដោយលាយល័ក្ខណ៍អក្សរ ឬដោយមាត់ទទេ ទោះចំពោះការងារដែលបានធ្វើក្តី ឬដែលត្រូវធ្វើក្តី ចំពោះសេវាដែលបានបំពេញ ឬត្រូវបំពេញក្តី។

<u>មាត្រា ១៦១៖</u>

- ❖ រៀងរាល់ឆ្នាំ ក្រសួងទទួលបន្ទុកការងារចេញប្រកាសកំណត់ថ្ងៃបុណ្យដែលត្រូវឈប់មានប្រាក់ឈ្នួលសំរាប់កម្មករនិយោជិត ក្នុងសហគ្រាសទាំងអស់។ ថ្ងៃបុណ្យឈប់សំរាក មានប្រាក់ឈ្នួលទាំងឡាយនេះមិនផ្តាច់លើថេរវេលាធ្វើការដែលត្រូវគិតដើម្បីឲ្យឈប់សំរាកប្រចាំថ្ងៃ ឆ្នាំនោះដែរ។

<u>មាត្រា ១៦២៖</u>

- ❖ ក្នុងករណីថ្ងៃបុណ្យដែលត្រូវបានឈប់សំរាកត្រូវចំលើថ្ងៃអាទិត្យនោះ កម្មករនិយោជិតនឹងត្រូវបានឈប់សំរាកមួយថ្ងៃ (១ថ្ងៃ) បន្តទៀត។ ការឈប់សំរាកថ្ងៃបុណ្យមិនមែនជាហេតុនាំឲ្យបន្ថយប្រាក់ឈ្នួលប្រចាំខែ ប្រចាំអឌ្ឍមាស ឬប្រចាំសប្តាហ៍ឡើយ។

<u>មាត្រា ១៦៣៖</u>

- ❖ កម្មករនិយោជិតធ្វើការតាមម៉ោងប្រចាំថ្ងៃឬតាមបរិមាណផលិតផល ត្រូវមានសិទ្ធិតាមប្រាក់បំណាច់ស្មើនឹងប្រាក់ឈ្នួលបង់ខាត មកពីការឈប់បុណ្យដូចមានចែងក្នុងមាត្រា១៦១ខាងលើ។ ប្រាក់បំណាច់នេះត្រូវនៅក្នុងបន្ទុកនៃនិយោជក។

<u>មាត្រា ១៦៤៖</u>

- ❖ នៅក្នុងគ្រឹះស្ថានសហគ្រាសណាដែលមិនអាចបញ្ឈប់ការងារបាន ដោយសារសកម្មភាពរបស់ខ្លួនតំរូវឲ្យកម្មករនិយោជិតទាំងឡាយ ដែលជាប់ធ្វើការក្នុងថ្ងៃឈប់បុណ្យ ត្រូវមានសិទ្ធិទទួលក្រៅអំពីប្រាក់ឈ្នួលនៃការងារដែលខ្លួនបានធ្វើនូវប្រាក់បំណាច់មួយដែលនៅលើបន្ទុកនិយោជកដែរ ហើយដែលកំរិតក្នុងប្រកាសក្រសួងទទួលបន្ទុកវិស័យការងារ។

**៣.៤.២ ការឈប់សំរាកពិសេស**

<u>មាត្រា ១៧១៖</u>

- ❖ និយោជកមានសិទ្ធិអនុញ្ញាតឲ្យកម្មករនិយោជិតខ្លួនឈប់សំរាក ជាពិសេសក្នុងឱកាសមានព្រឹត្តិការណ៍ដែលប៉ះពាល់ផ្ទាល់ដល់គ្រួសារនៃកម្មករនិយោជិត។

- ❖ ក្នុងករណីដែលកម្មករនិយោជិត មិនទាន់អនុវត្តការឈប់សំរាកប្រចាំឆ្នាំទាំងអស់របស់ខ្លួនទេ និយោជកមិនអាចធ្វើការកាត់កងការឈប់សំរាកពិសេសខាងលើ ពីការឈប់សំរាកប្រចាំឆ្នាំរបស់កម្មករនិយោជិតបានទេ។

- ❖ ក្នុងករណីដែលកម្មករនិយោជិតបានអនុវត្តការឈប់សំរាកប្រចាំឆ្នាំរបស់ខ្លួនរួចអស់ហើយ និយោជកមិនអាចធ្វើការកាត់កងការឈប់សំរាកពិសេសខាងលើ ពីការឈប់សំរាកប្រចាំឆ្នាំសំរាប់ឆ្នាំខាងមុខរបស់កម្មករ និងនិយោជិតបានទេ។

- ម៉ោងធ្វើការដែលខាតបង់ក្នុងឱកាសឈប់សំរាកពិសេសនេះអាចនឹងបំពេញវិញបានតាមល័ក្ខខ័ណ្ឌ ដូចមានក្នុងកំរិតប្រកាសក្រសួងទទួលបន្ទុកវិស័យការងារ។

### ៣.៤.៣ អនាម័យ និងសន្តិសុខនៃកម្មករនិយោជិត

<u>មាត្រា ២៣៨៖</u>

- សហគ្រាស និងគ្រឹះស្ថានដែលចង្អុលក្នុងមាត្រា១ នៃច្បាប់នេះត្រូវរៀបចំឲ្យមានការព្យាបាលបឋម សំរាប់កម្មករនិយោជិតរបស់ខ្លួន។

<u>មាត្រា ២៣៩៖</u>

- ក្រុមពេទ្យការងារត្រូវដឹកនាំដោយពេទ្យម្នាក់ ឬច្រើននាក់ដោយមាននាមជាគ្រូពេទ្យការងារ ដែលមានភារកិច្ចការពារព្យាបាលកុំឲ្យខូចសុខភាពអ្នកធ្វើការដែលបណ្តាលមកពីការងាររបស់គេ ពិសេសឃ្លាំមើលល័ក្ខខ័ណ្ឌអនាម័យការងារ គ្រោះថ្នាក់នៃជម្ងឺឆ្លង និងស្ថានភាពសុខភាពអ្នកជម្ងឺ។

<u>មាត្រា ២៤០៖</u>

- ក្រុមពេទ្យការងារ អាចមានជាពិសេសសំរាប់សហគ្រាសនីមួយៗ ឬមានក្រុមពេទ្យការងារមួយ សំរាប់សហគ្រាសច្រើន ប្រើប្រាស់រួមគ្នាតាមសារៈសំខាន់នៃសហគ្រាស។
- គិលានដ្ឋាននេះ ត្រូវមានគ្រូពេទ្យកាន់កាប់ផ្ទាល់ ដោយមានគិលានុប្បដ្ឋាក ឬគិលានុប្បដ្ឋាយិកាម្នាក់ ឬច្រើននាក់ជួយធ្វើការផងគិតទៅតាមចំនួនកម្មករនិយោជិត។
- ក្នុងម៉ោងធ្វើការទាំងថ្ងៃទាំងយប់ត្រូវមានគិលានុប្បដ្ឋាកឬគិលានុប្បដ្ឋាយិកាយ៉ាងតិចម្នាក់នៅយាមប្រចាំការជាអចិន្ត្រៃយ៍។

<u>មាត្រា ២៤៣៖</u>

- កាលណាដែលសហគ្រាសដែលចង្អុលក្នុងមាត្រា២២៨ មានសាខា ឬការដ្ឋានមួយ ឬច្រើនដែលមានប្រើកម្មករនិយោជិតយ៉ាងតិចហាសិប (៥០នាក់) ហើយស្ថិតនៅចម្ងាយលើសពីប្រាំ(០៥)គីឡូម៉ែត្រពីការដ្ឋានធំ និយោជកត្រូវតែផ្តល់ចំពោះសាខា ឬការដ្ឋានទាំងនេះឲ្យដូចចំពោះការដ្ឋានធំនូវមធ្យោបាយសង្គ្រោះ និងព្យាបាលកម្មករនិយោជិតខ្លួនឲ្យបានសព្វគ្រប់ ដូចជាបុគ្គលិកពេទ្យ សំណង់ សំភារៈ វត្ថុរំរបួស និងថ្នាំព្យាបាល។

<u>មាត្រា ២៤៥៖</u>

- ក្រៅពីវិធានការដែលចែងក្នុងមាត្រាខាងលើ និយោជកត្រូវចាត់ចែងដោយចេញសោហ៊ុយខ្លួនឯងនូវៈ

  ១- ក្រុមគីមីបង្ការរោគ នៅក្នុងការដ្ឋានខ្លួន

  ២- ការចាក់ថ្នាំការពារជម្ងឺឆ្លងទាំងឡាយ។
- ក្នុងពេលមានជម្ងឺឆ្លង ក្រសួងសុខាភិបាលអាចតម្រូវឲ្យមានចាត់វិធានការការពារ ជាពិសេសនៅក្នុងការដ្ឋានទាំងអស់។ (ដកស្រង់ពីឯកសារច្បាប់ស្តីពីការងារ ខែតុលា ឆ្នាំ១៩៩៨)។



Draft

## ៣.៥ ច្បាប់ស្តីពីជលផល

៥. ច្បាប់ស្តីពីជលផល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យ និងផ្តល់យោបល់លើអត្ថបទច្បាប់នេះ ស្របតាមមាត្រា ១១៣ថ្មីនៃរដ្ឋធម្មនុញ្ញហើយ ហើយច្បាប់ស្តីពីជលផលត្រូវបានប្រកាសជាផ្លូវការឲ្យប្រើប្រាស់តាមព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ៖

__មាត្រា១៖__ ច្បាប់នេះមានគោលបំណងធានានូវការគ្រប់គ្រងជលផល និងធនធានជលផល ជំរុញកិច្ចអភិវឌ្ឍន៍វារីវប្បកម្ម ផលិតកម្ម និងការកែច្នៃលើកស្ទួយជីវភាពរស់នៅរបស់ពលរដ្ឋក្នុងសហគមន៍មូលដ្ឋានដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវចម្រុះផង ទាំងមរតកវប្បធម៌ធម្មជាតិផង ប្រកបដោយនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

__មាត្រា២៖__ ច្បាប់នេះមានវិសាលភាពអនុវត្តលើជលផលទាំងអស់ ទាំងប្រភេទជលផលដែលកើតឡើងដោយធម្មជាតិទាំងផលកែច្នៃ និងទាំងវារីវប្បកម្ម។ រដ្ឋធានាសិទ្ធិប្រើប្រាស់ធនធានជលផលជាប្រពៃណីរបស់សហគមន៍មូលដ្ឋានក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ឬច្បាប់ពាក់ព័ន្ធផ្សេងទៀត។

__មាត្រា៤៖__ ធនធានជលផលមានសរីរាង្គទឹកសាប និងសមុទ្រ ជាសត្វ និងរុក្ខជាតិ មានជីវិត ឬគ្មានជីវិតជាអាទិ៍ មច្ឆជាតិ សិប្បីសត្វ ថលជលិកសត្វ បាណកសត្វ ឧរង្គសត្វ ថនិកសត្វ សត្វឥតឆ្អឹងកងផ្សេងទៀតដែលបង្កកំណើតនៅក្នុងទឹក ប្លង់តុង សារាយ ស្មៅសមុទ្រ ផ្កាថ្ម ព្រៃលិចទឹក ព្រមទាំងព្រៃកោងកាងជាដើម។

__មាត្រា៦៖__ រដ្ឋបាលជលផល គឺជាអាជ្ញាធររដ្ឋាភិបាលដែលចំណុះក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចគ្រប់គ្រងជលផល និងធនធានជលផលស្របតាមគោលនយោបាយវិស័យជលផលជាតិ និងខ្លឹមសារនៃច្បាប់នេះ។ រដ្ឋបាលជលផលមានរចនាសម្ព័ន្ធគ្រប់គ្រងចាត់តាំងមួយឯកភាពទូទាំងប្រទេសជាខ្សែរយៈបណ្តោយដែលបែងចែកជាថ្នាក់កណ្តាល អធិការដ្ឋាន ខណ្ឌ ផ្នែក និងសង្កាត់រដ្ឋបាលជលផល។ ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពរបស់រដ្ឋបាលជលផលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

__មាត្រា៨៖__ ដែននេសាទរួមមាន ដែនដីលិចទឹកអចិន្ត្រៃយ៍ ដែនដីដែលទទួលរបបទឹកទន្លេមេគង្គ និងដែនដីទទួលរបបទឹកជោរ នាចនៃសមុទ្រ ដែលមានតួនាទីសំខាន់បម្រើឲ្យការនេសាទគ្រប់ប្រភេទ និងការការពារប្រព័ន្ធអេកូឡូស៊ីជលផល។ ដែនដីលិចទឹកអចិន្ត្រៃយ៍មានជាអាទិ៍ សមុទ្រ ទន្លេ ដៃទន្លេ បឹង ព្រែក ស្ទឹងអូរ អាងទឹក និងប្រឡាយ។ ដែនដីដែលទទួលរបបទឹកទន្លេមេគង្គមានជាអាទិ៍ ត្រពាំង រណ្តៅ វាលភក់ ល្បាប់ វាលទំនាបដែលលិចទឹកក្នុងរដូវទឹកជំនន់ និងនាទីព្រៃលិចទឹក។ ដែនដីដែលទទួលរបបទឹកជោរនាចនៃ សមុទ្រមានជាអាទិ៍ព្រៃកោងកាង។

__មាត្រា៩៖__ ដែននេសាទជាទ្រព្យសម្បត្តិរបស់រដ្ឋ។ ព្រំប្រទល់នៃដែននេសាទត្រូវកំណត់ដោយអនុក្រឹត្យ។ រាល់ការប្រើប្រាស់ដែននេសាទ ដើម្បីគោលបំណងក្រៅវិស័យជលផល ត្រូវមានការសម្រេចពីរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ដែននេសាទអាចគ្របដណ្តប់លើដីសាធារណៈ ឬដីកម្មសិទ្ធិឯកជនរដូវទឹកជំនន់ ប៉ុន្តែការគ្រប់គ្រងជលផល មិនប៉ះពាល់ដល់ដីកម្មសិទ្ធិទាំងនោះឡើយ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិឲ្យប្រើប្រាស់ដែននេសាទ ទៅតាមបទបញ្ញត្តិនៃច្បាប់នេះ ដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដើម្បីធ្វើអាជីវកម្មនេសាទប្រមូលធនធានជលផល ស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផល ឬតម្រូវការចាំបាច់ផ្សេងៗទៀត។

**<u>មាត្រា១២៖</u>** កន្លែងនេសាទគ្រប់ប្រភេទ កន្លែងអភិរក្សជលផល តំបន់ស្មៅសមុទ្រតំបន់ផ្កាថ្ម ទំនាបលិចទឹកក្នុងរដូវទឹកជំនោរដូនាទីព្រៃលិចទឹក និងនាទីព្រៃកោងកាងដូចមាន ចែងក្នុងមាត្រា១០ និងមាត្រា១១ នៃច្បាប់នេះគឺជាតំបន់គ្រប់គ្រងជលផល។ ការបង្កើត ការរំសាយតំបន់គ្រប់គ្រងជលផល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ នីតិវិធីនៃការបង្កើត ឬរំសាយតំបន់គ្រប់គ្រងជលផលត្រូវកំណត់ដោយអនុក្រឹត្យ។

**<u>មាត្រា១៣៖</u>** ការផ្តល់កម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ដីធ្លីនៅក្នុងតំបន់គ្រប់គ្រងជលផលអាចប្រព្រឹត្តទៅបានលុះត្រាតែមានការសិក្សាវាយតម្លៃពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**<u>មាត្រា១៦៖</u>** រដូវបិទនេសាទសម្រាប់ការនេសាទសិប្បកម្ម ត្រូវកំណត់ដូចខាងក្រោម៖

១-ចាប់ពីថ្ងៃទី០១ ខែមិថុនា ដល់ថ្ងៃទី៣០ ខែកញ្ញា ចំពោះដែននេសាទទឹកសាប ដែលស្ថិតនៅខាងជើងខ្សែស្របទន្លេចតុមុខ (រយៈទទឹងៈ ១១°៣៣,២៥៩'ជើង។

២-ចាប់ពីថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣១ ខែតុលា ចំពោះដែននេសាទទឹកសាបដែលស្ថិតនៅខាងត្បូងខ្សែស្របទន្លេចតុមុខ (រយៈទទឹងៈ ១១°៣៣,២៥៩'ជើង)។

៦. រដ្ឋបាលជលផលត្រូវទទួលបន្ទុកស្រាវជ្រាវ និងតាមដានរដូវត្រីពងកូនរដូវនេសាទសម្រាប់តំបន់ ឬប្រភេទធនធានជលផលដទៃទៀត។ រដូវត្រីពងកូន រដូវនេសាទសម្រាប់តំបន់ ឬប្រភេទធនធានជលផលដទៃទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**<u>មាត្រា១៧៖</u>** ដើម្បីជំរុញការអប់រំប្រជាពលរដ្ឋឲ្យយល់ពីសារៈសំខាន់ និងផលប្រយោជន៍នៃជលផល ទិវាលែងត្រី ឬវារីសត្វជាប្រពៃណីជាតិហៅថា **ទិវាមច្ឆាជាតិ** ត្រូវប្រារព្ធធ្វើឡើងនៅថ្ងៃទី០១ ខែកក្កដាជា រៀងរាល់ឆ្នាំ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ឬ ព្រះរាជ តំណាង។

**<u>មាត្រា១៨៖</u>** តំបន់គ្រប់គ្រងជលផលជាអាទិ៍ តំបន់ទឹកជ្រៅ អន្លង់ជ្រៅៗនៅតាមដងទន្លេ បឹងទន្លេសាប បឹងព្រៃលិចទឹក តំបន់កោះ តំបន់ស្មៅសមុទ្រ តំបន់ផ្កាថ្ម និងព្រៃកោងកាង ដែលជាកន្លែងមានសារៈសំខាន់ដល់និរន្តរភាពនៃធនធានជលផល ត្រូវរៀបចំចាត់ថ្នាក់ជាកន្លែងការពារ និងអភិរក្សធនធានជលផល។

**<u>មាត្រា២០៖</u>** ហាមឃាត់ដាច់ខាត ចំពោះការធ្វើនេសាទគ្រប់ប្រភេទនៅក្នុងដែននេសាទ ដោយប្រើឧបករណ៍ដូចខាងក្រោមៈ

- ឧបករណ៍ឆក់ គ្រឿងផ្ទុះ និងសារធាតុពុលគ្រប់ប្រភេទ។
- ឧបករណ៍បូម បាច ពង្រីងផ្នែកណាមួយនៃដែននេសាទ ដែលបង្កមហន្តរាយដល់ធនធានជលផល។
- សម្រាប់ ឬមធ្យោបាយផ្សេងទៀតដែលធ្វើឲ្យត្រី ឬវារីសត្វកុំ។



Draft

- ❖ ចប្រូក សាង ស្ន ឬឧបករណ៍បាញ់ព្រួញដែលរួមផ្សំគ្រឿងផ្ទុះ។
- ❖ មងបោះ មងកាំង ឬមងពស់ថ្លាន់គ្រប់ប្រភេទ។
- ❖ មង ឬអួន គ្រប់ប្រភេទដែលមានក្រឡាតូចជាងមួយសង្ទីម៉ែត្រកន្លះ (១.៥ស.ម) ក្នុងដែននេសាទទឹកសាប។
- ❖ មងគ្រប់ប្រភេទដែលមានក្រឡាធំជាងដប់ប្រាំ(១៥) សង្ទីម៉ែត្រក្នុងដែននេសាទទឹកសាប។
- ❖ អួនអូសគូ ឬអួនហ៊ុមរួមផ្សំភ្លើងដែលធ្វើឲ្យត្រី ឬវារីសត្វកុំ។
- ❖ អួនអូសគ្រប់ប្រភេទនៅទឹកសាប និងឈិបយន្ត។
- ❖ ព្រួលគ្រប់ប្រភេទ ដែលមានចន្លោះពីត្រៀមមួយទៅត្រៀមមួយ តូចជាងមួយសង្ទីម៉ែត្រកន្លះ (១.៥ស.ម)។
- ❖ ខ្សែចងគ្រប់ប្រភេទ និងមធ្យោបាយផ្សេងៗទៀត ដែលបង្កលក្ខណៈឲ្យត្រីផ្អើល។
- ❖ ទំនប់រួមផ្សំដោយឧបករណ៍នេសាទគ្រប់ប្រភេទ។
- ❖ ឧបករណ៍នេសាទទំនើប ឬឧបករណ៍នេសាទដែលបង្កើតថ្មី ឬរបៀបនេសាទបែបថ្មី ដែលនាំមកនូវការបំផ្លាញមច្ឆាជាតិ ធនធានជលផល ប្រព័ន្ធអេកូឡូស៊ីជលផល ឬដែលគ្មានកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

<u>មាត្រា២១៖</u> ហាមឃាត់ការផលិត ការទិញ ការលក់ ការដឹកជញ្ជូន ការរក្សាទុកឧបករណ៍ឆក់ ឧបករណ៍នេសាទ ស្បៃមុងគ្រប់ប្រភេទ អួនអូសគូ ឈិបយន្ត និងអួនអូសទឹកសាប ក្នុងបំណងធ្វើនេសាទ។

<u>មាត្រា២២៖</u> ហាមឃាត់ការចាក់ចោល ការបោះចោល ការបង្ហូរ ឬការបានពង្រាយទៅក្នុងដែននេសាទ នូវកាកសំណល់រឹងឬរាវ ឬសារធាតុពុលដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញា ឬសន្ធិសញ្ញាអន្តរជាតិស្តីពីការបំពុលបរិស្ថាន ឬការប្រព្រឹត្តសកម្មភាព ដែលធ្វើឲ្យពុល ឬការបង្កគ្រោះថ្នាក់ដល់វារីសត្វ និងវារីរុក្ខជាតិ។

<u>មាត្រា២៣៖</u> សកម្មភាពដូចខាងក្រោមអាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាតៈ

- ❖ ការចាប់ ការលក់ ការទិញ ការធ្វើសន្និធិ និងការដឹកជញ្ជូនកូន ឬពងត្រី និងកូន ឬពងវារីសត្វផ្សេងៗទៀត។
- ❖ ការចាប់ ការលក់ ការទិញ ការដឹកជញ្ជូន ការប្រមូលផល ការកែច្នៃ និងការធ្វើសន្និធិនូវប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់។
- ❖ ការដាំ ឬការថែរក្សាដំណាំឈូកក្នុងដែននេសាទ។
- ❖ ការពង្រីកផ្ទៃដីស្រែចម្ការ ឬស្រែអំបិលក្នុងដែននេសាទ។
- ❖ ការគាស់ ការកកាយយកថ្ម ដីខ្សាច់ និងរ៉ែ ដែលមាននៅក្នុងដែននេសាទ។
- ❖ ការទិញ ឬការលក់សំបកពពួកខ្យងខ្ទៅតាំងលំអដែលជាប្រភេទកម្រ។
- ❖ ការនេសាទដោយឧបករណ៍ម៉ាញ់ នាម ជន មងក្រឡុក មងអូស ឈ្នាងអូសលៀស ឬខ្ទៅ នៅទឹកសាម និងឈ្នាងអូសគ្រែងឈាមនៅតំបន់ឆ្នេរសមុទ្រដែលអូស ឬរុញដោយកម្លាំង ម៉ាស៊ីន។

Draft

៧. ទំហំកូនត្រីវារីសត្វផ្សេងៗទៀត និងប្រភេទសំបកខ្យងខ្ចៅតាំងលំអ ដែលជាប្រភេទកម្រត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា២៤៖** ហាមឃាត់:

- ការបោះបង្គោលបង្កើតឡូត៍នេសាទថ្មីដោយគ្មានការអនុញ្ញាត។
- ការផ្លាស់ប្តូរ ការរំកិល ការដកកប់ ឬការបំផ្លាញបង្គោលព្រំប្រទល់នៃតំបន់គ្រប់គ្រងជលផល។
- ការនេសាទគ្រប់ប្រភេទធ្វើឲ្យរាំងស្ទះចរាចរណ៍ត្រីចុះនៅតំបន់បឹងទន្លេសាប។
- ការនេសាទដោយលបណ ឬ រ៉ាវ ក្រៅតំបន់កំណត់។
- ការធ្វើអាជីវកម្មនេសាទ ការធ្វើវារីវប្បកម្ម ការដឹកជញ្ជូនការកែច្នៃ និងសន្និធិផល ផលិតផលជលផល ខុសពីការកំណត់ក្នុងលិខិតអនុញ្ញាត។
- ការបង្កើតទីតាំងទិញ លក់សន្និធិ ផែត្រី កន្លែងកែច្នៃផល ផលិតផលជលផលជាលក្ខណៈសិប្បកម្ម ឬឧស្សាហកម្មខុសពីការកំណត់ក្នុងលិខិតអនុញ្ញាត។
- ការប្រើប្រាស់ឧបករណ៍នេសាទ និងមធ្យោបាយគ្រប់ប្រភេទខុសពីការកំណត់ក្នុងលិខិត អនុញ្ញាត។
- ការផ្ទេរលិខិតអនុញ្ញាតគ្រប់ប្រភេទដោយគ្មានការអនុញ្ញាតពីរដ្ឋបាលជលផល។
- ការធ្វើសកម្មភាពដទៃទៀតនៅក្នុងដែននេសាទដែលបង្កអន្តរាយដល់ប្រភពធនធានជលផល។

**មាត្រា២៥៖** ការធ្វើទំនប់កាត់ ឬការលុបទន្លេ ស្ទឹង ព្រែក អូរ បឹង ប្រឡាយ អាងទឹក និងអាងធម្មជាតិ ឬការជីកប្រឡាយ រណ្តៅ និងស្រះទ្រង់ទ្រាយធំ ឬការសាងសង់សំណង់ថ្មីនានា ឬការបូមទឹកដែលអាចបង្ករក្ខាប្រមាញ់ និងនេសាទ និងស្ថាប័នពាក់ព័ន្ធ។

**មាត្រា២៧៖** តំបន់លិចទឹកដែលត្រូវការពារមានជាអាទិ៍ ដីលិចទឹកដែលស្ថិតនៅក្នុងនាទីឡូត៍នេសាទនិងស្ថិតនៅក្នុងនាទីព្រៃលិចទឹក និងព្រៃកោងកាងដែលត្រូវការពារសម្រាប់ដាំ ឬរក្សាទុកឲ្យដុះព្រៃឡើងវិញដើម្បីរក្សាលំនឹងប្រព័ន្ធអេកូឡូស៊ីជលផល។

**មាត្រា២៨៖** ហាមឃាត់:

- ការពង្រីកផ្ទៃដីកសិកម្ម ឬការប្រើប្រាស់ដីក្នុងបំណងផ្សេងៗ ក្រៅពីកិច្ចអភិវឌ្ឍន៍វិស័យជលផលនៅក្នុងតំបន់លិចទឹកដែលត្រូវការពារស្របតាមបទបញ្ញត្តិនៃច្បាប់នេះ។
- ការផ្តល់កម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ដីធ្លីនៅក្នុងតំបន់លិចទឹកដែលត្រូវការពារ។
- ការកាប់ ការឆ្ការ ការគាស់ ការរាន ការឈូសឆាយ ការដុត ឬការហ៊ុមព័ទ្ធកាន់កាប់ព្រៃលិចទឹក និងព្រៃកោងកាង។
- ការកាប់បំផ្លាញផ្តួលរំលំដើមឈើព្រៃលិចទឹក និងព្រៃកោងកាង ឬគាស់រំលើងប្រមូលគល់ឈើព្រៃលិចទឹក និងព្រៃកោងកាង។
- ការប្រមូល ដឹកជញ្ជូន និងការធ្វើសន្និធិឈើ អុស ធ្យូង ប្រភេទឈើព្រៃលិចទឹក និងព្រៃកោងកាងជាលក្ខណៈអាជីវកម្ម ឬពាណិជ្ជកម្ម។

- ការសាងសង់ឡ រោងសិប្បកម្ម មូលដ្ឋានកែច្នៃនិងរោងចក្រគ្រប់ប្រភេទ ដែលប្រើប្រាស់វត្ថុធាតុដើមជាប្រភេទឈើព្រៃលិចទឹក និងព្រៃកោងកាង។

**មាត្រា២៩៖** រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានទទួលសិទ្ធិធ្វើអាជីវកម្មឡូត៍នេសាទត្រូវមានកាតព្វកិច្ចរក្សាការពារព្រៃលិចទឹក និងទ្រព្យសម្បត្តិរបស់រដ្ឋនៅក្នុងនាទីឡូត៍នេសាទ។

**មាត្រា៣០៖** ការធ្វើនេសាទត្រូវកំណត់តាមឧបករណ៍នេសាទបីប្រភេទ:

- ឧបករណ៍នេសាទគ្រួសារ។
- ឧបករណ៍នេសាទសិប្បកម្ម។
- ឧបករណ៍នេសាទឧស្សាហកម្ម។

៨. ប្រភេទឧបករណ៍នេសាទខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៣១៖** ការធ្វើនេសាទជាលក្ខណៈគ្រួសារ អាចប្រព្រឹត្តទៅបានគ្រប់ពេលវេលា នៅក្នុងកន្លែងនេសាទបម្រុងនៅក្នុងកន្លែងនេសាទគ្រួសារ នៅក្នុងឡូត៍នេសាទនៃដែននេសាទទឹកសាបក្នុងរដូវបិទនេសាទ ឬនៅក្នុងដែននេសាទសមុទ្រ ដោយប្រើឧបករណ៍នេសាទគ្រួសារ។ ការធ្វើនេសាទជាលក្ខណៈសិប្បកម្ម អាចប្រព្រឹត្តទៅបានតែនៅក្នុងកន្លែងនេសាទបម្រុងនៃដែននេសាទទឹកសាប ឬនៅក្នុងដែននេសាទសមុទ្រ ដោយប្រើឧបករណ៍នេសាទសិប្បកម្ម។ ការធ្វើនេសាទជាលក្ខណៈឧស្សាហកម្ម អាចប្រព្រឹត្តទៅបានតែនៅក្នុងកន្លែងនេសាទបម្រុងនៃដែននេសាទទឹកសាប ឬនៅក្នុងដែននេសាទសមុទ្រដោយប្រើឧបករណ៍នេសាទឧស្សាហកម្ម។

**មាត្រា៣២៖** ការធ្វើអាជីវកម្មនេសាទគ្រប់ប្រភេទនៅក្នុងដែននេសាទទឹកសាប ឬសមុទ្រលើកលែងតែការធ្វើនេសាទជាលក្ខណៈគ្រួសារត្រូវ:

- មានលិខិតអនុញ្ញាតឲ្យធ្វើអាជីវកម្មនេសាទ។
- មានកាតព្វកិច្ចបង់ពន្ធ និងថ្លៃឈ្នួលនេសាទជូនរដ្ឋ។
- គោរពតាមបទបញ្ញាដែលមានចែងក្នុងលិខិតអនុញ្ញាតឲ្យធ្វើនេសាទ។

៩. ការប្រគល់ឡូត៍នេសាទឲ្យធ្វើអាជីវកម្ម អាចប្រព្រឹត្តទៅបានតាមការវិនិយោគ តាមការដេញថ្លៃជាសាធារណៈ ឬជួលតាមការព្រមព្រៀងចំពោះឡូត៍នេសាទដែលគ្មានអ្នកដេញថ្លៃ។

នីតិវិធីនៃការវិនិយោគ ការដេញថ្លៃជាសាធារណៈឬការជួលតាមការព្រមព្រៀង និងការបង់ថ្លៃឈ្នួលនេសាទត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៣៖** បន្ថែមលើច្បាប់ផ្សេងទៀត ដែលពាក់ព័ន្ធទៅលើការគ្រប់គ្រងនាវាអាជីវកម្មនេសាទទាំងអស់ដែលប្រើប្រាស់នាវានេសាទក្នុងដែននេសាទនៃព្រះរាជាណាចក្រកម្ពុជា ត្រូវសុំចុះបញ្ជីនាវា និងឧបករណ៍បរិក្ខាបម្រើការធ្វើនេសាទពីរដ្ឋបាលជលផល បន្ទាប់ពីបានត្រួតពិនិត្យតាមគោលការណ៍បច្ចេកទេស។ បទបញ្ញាបច្ចេកទេសនៃការគ្រប់គ្រងនាវានេសាទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

<u>**មាត្រា៣៤៖**</u> គ្រប់សកម្មភាពធ្វើអាជីវកម្មនេសាទ ធ្វើវារីវប្បកម្ម ធ្វើសន្និធិកែច្នៃ និងទិញ លក់ផល ផលិតផលជលផល ដែលតម្រូវឲ្យមានលិខិតអនុញ្ញាត សៀវភៅសម្រាប់កត់ត្រាស្ថិតិ ដែលចេញដោយរដ្ឋបាលជលផលមានសមត្ថកិច្ច។ សៀវភៅកត់ត្រាស្ថិតិនេះចាំបាច់ត្រូវមានការកត់ត្រាស្ថិតិឲ្យបានទៀងទាត់ជារៀងរាល់ថ្ងៃ និងត្រូវចុះហត្ថលេខាបញ្ជាក់ពីរដ្ឋបាលជលផលមានសមត្ថកិច្ចរៀងរាល់ខែ។

<u>**មាត្រា៣៥៖**</u> ការធ្វើសន្និធិផល ផលិតផលជលផលក្នុងរដូវបិទនេសាទ អាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាត។ អាជីវករនេសាទត្រូវដាក់ពាក្យសុំធ្វើសន្និធិទៅរដ្ឋបាលជលផលយ៉ាងតិចដប់ប្រាំ (១៥) ថ្ងៃមុនរដូវបិទនេសាទ។

<u>**មាត្រា៣៦៖**</u> ការបង្កើតទីតាំងទិញលក់សន្និធិ ឬកន្លែងកែច្នៃផល ផលិតផលជលផលតាមទ្រង់ទ្រាយសិប្បកម្ម ត្រូវមានលិខិតអនុញ្ញាតពីរដ្ឋបាលជលផលមានសមត្ថកិច្ច។ ការបង្កើតទីតាំងកែច្នៃផលផលិតផលជលផលតាមទ្រង់ទ្រាយឧស្សាហកម្មត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ។

<u>**មាត្រា៣៧៖**</u> ការបង្កើតផែត្រីដែលជាកន្លែងប្រមូលផ្តុំ ចែកចាយ ធ្វើពាណិជ្ជកម្មផលផលិតផលជលផលត្រូវមានលិខិតអនុញ្ញតពីរដ្ឋបាលជលផលមានសមត្ថកិច្ច។ វិធាននៃការបង្កើតនិងការគ្រប់គ្រងផែត្រីត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

<u>**មាត្រា៣៨៖**</u> ការធ្វើអាជីវកម្មនេសាទ ឬវារីវប្បកម្មរបស់ជនបរទេសត្រូវស្ថិតនៅក្រោមកិច្ចព្រមព្រៀងជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្ទាប់ពីបានទទួលគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា។

<u>**មាត្រា៣៩៖**</u> ការធ្វើអាជីវកម្មនេសាទក្នុងឡូត៍នេសាទ អាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាត ហើយត្រូវធ្វើតែនៅក្នុងរយៈពេលបើកនេសាទដែលមានកំណត់ក្នុងសៀវភៅបន្ទុក ឬលិខិតអនុញ្ញាតឲ្យធ្វើនេសាទ នឹងត្រូវអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងសៀវភៅបន្ទុក។ គំរូសៀវភៅបន្ទុកឡូត៍នេសាទដែលបានរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

<u>**មាត្រា៤០៖**</u> ក្នុងរដូវបើកនេសាទ ទីតាំងនេសាទទាំងឡាយដែលធ្វើកាត់ផ្លូវទឹកក្នុងឡូត៍នេសាទ ត្រូវបើកមុខទឹកសម្រាប់ឲ្យជលយានគ្រប់ប្រភេទអាចធ្វើចរាចរណ៍បាន ហើយមិនត្រូវធ្វើឲ្យទឹកចាល់នៅមុខរបាំងទេ។ ក្នុងរដូវបិទនេសាទ ត្រូវរុះរើនិងដកចេញនូវទីតាំងនេសាទទាំងឡាយដែលនៅក្នុងឡូត៍នេសាទឲ្យបានមុខថ្ងៃទី ១៥ ខែ មិថុនា ចំពោះតំបន់ដែលស្ថិតនៅខាងជើងខ្សែស្របទន្លេចតុមុខ និងមុនថ្ងៃទី១៥ ខែកក្កដា ចំពោះតំបន់ដែលស្ថិតនៅខាងត្បូងខ្សែស្របទន្លេចតុមុខ។

<u>**មាត្រា៤២៖**</u> ផ្ទុយនឹងបទបញ្ញត្តិដែលមានចែងក្នុងចំណុច៣ មាត្រា៤១ នៃច្បាប់នេះ ការធ្វើនេសាទ នៅក្នុងកន្លែងនេសាទបម្រុងដោយ លប ណ ឬរ៉ាវ ដែលមានប្រវែងតិចជាង (៥០០) ម៉ែត្រនៅក្នុងបឹងទន្លេសាប អាចអនុញ្ញាតឲ្យធ្វើបានពីថ្ងៃទី ១ ខែ កុម្ភៈ ដល់ថ្ងៃទី២០ ខែឧសភា នៅក្នុងកន្លែងដែលមានចម្ងាយយ៉ាងច្រើនបំផុតបួន (៤) គីឡូម៉ែត្រពីមាត់ច្រាំង និងមួយ (១) គីឡូម៉ែត្រយ៉ាងតិចពីព្រំប្រទល់កន្លែងអភិរក្សជលផលហើយនិងនៅក្នុងតំបន់ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

១០. ការបោះទីតាំង លប ណ ឬរ៉ាវនេះ មិនត្រូវធ្វើឲ្យរាំងស្ទះផ្លូវដែលយានគ្រប់ប្រភេទទេ។ ទីតាំងលប ណ ឬរ៉ាវទាំងឡាយ ត្រូវដកចេញឲ្យអស់មុនថ្ងៃទី៣១ ខែឧសភាជាចំខាត។

<u>មាត្រា៤៣៖</u> ការធ្វើនេសាទជាលក្ខណៈសិប្បកម្មដោយអួន ទោះជាមួយវង់ ឬច្រើនវង់តភ្ជាប់គ្នាក៏ដោយ អាចប្រព្រឹត្តទៅបាន លុះត្រាតែអួននោះមានបណ្តោយតិចជាងៈ

- បីរយ (៣០០) ម៉ែត្រចំពោះកន្លែងនេសាទបម្រុងនៅក្រៅបឹងទន្លេសាប
- ប្រាំមួយរយ(៦០០) ម៉ែត្រ ចំពោះកន្លែងនេសាទបម្រុងនៅក្នុងបឹងទន្លេសាប។

១១. មិនអនុញ្ញាតឲ្យធ្វើនេសាទជាលក្ខណៈសិប្បកម្មដោយអួន នៅក្នុងកន្លែងនេសាទដែលទុកសម្រាប់តែប្រជាពលរដ្ឋ នៅក្នុងកន្លែងនេសាទដែលធ្វើឲ្យរំខានដល់ការធ្វើអាជីវកម្មឡូត៍នេសាទ និងនៅក្នុងកន្លែងនេសាទដែលមានទម្លាប់ធ្វើអាជីវកម្មនេសាទដោយប្រើឧបករណ៍តូចៗ។ កន្លែងនេសាទដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ ត្រូវកំណត់ដោយរបស់រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

<u>មាត្រា៤៤៖</u> ការធ្វើនេសាទជាលក្ខណៈគ្រួសារនៅក្នុងកន្លែងនេសាទគ្រួសារ ដែលជាបឹងតូចៗស្ថិតក្នុងនាទីឡូត៍នេសាទនារដូវបើកនេសាទអាចប្រព្រឹត្តទៅបាន លុះត្រាតែគោរពតាមបទបញ្ជាបច្ចេកទេស ដែលកំណត់ដោយរដ្ឋបាលជលផល។

<u>មាត្រា៥៣៖</u> ការធ្វើវារីវប្បកម្មទឹកសាបដូចខាងក្រោម អាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាតពីរដ្ឋបាលៈ

**១**- ស្រះដែលមានផ្ទៃក្រឡាសរុប លើសពីប្រាំពាន់ (៥០០០) ម៉ែត្រក្រឡា។

**២**- ស៊ងដែលមានផ្ទៃក្រឡាសរុប លើសពីពីរពាន់ (២០០០) ម៉ែត្រក្រឡា។

**៣**- បែដែលមានផ្ទៃក្រឡាសរុប លើសពីដប់ប្រាំ (១៥) ម៉ែត្រក្រឡា។

១២. ការធ្វើវារីវប្បកម្មក្រពើ កន្ធាយ អណ្តើក កង្កែប អន្ទង់ ពស់ដែលបង្កកំណើតក្នុងទឹក ឬប្រភេទធនធានជលផលដទៃទៀតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

<u>មាត្រា៥៦៖</u> រូបវន្តបុគ្គល ឬនិតិបុគ្គល ដែលមានបំណងធ្វើវារីវប្បកម្មគ្រប់ប្រភេទដូចមានចែងក្នុងមាត្រា ៥៣ មាត្រា៥៤ និងមាត្រា៥៥ នៃច្បាប់នេះ ត្រូវដាក់ពាក្យសុំមករដ្ឋបាលជលផលមានសមត្ថកិច្ច និងត្រូវអនុវត្តតាមបទបញ្ជាបច្ចេកទេសវារីវប្បកម្មដែលកំណត់ដោយប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល។ រូបវន្តបុគ្គល ឬនិតិបុគ្គលធ្វើវារីវប្បកម្មគ្រប់ប្រភេទដែលមិនតម្រូវឲ្យមានលិខិតអនុញ្ញាត ត្រូវចុះបញ្ជីក្នុងសៀវភៅស្ថិតិវារីវប្បកម្ម ដោយមន្ត្រីរដ្ឋបាលជលផលមានសម្ថកិច្ច។

<u>មាត្រា៥៧៖</u> រូបវន្តបុគ្គល ឬនិតិបុគ្គលដែលធ្វើវារីវប្បកម្មគ្រប់ប្រភេទត្រូវរក្សាគុណភាពដី ទឹក វារីជីវសាស្ត្របរិស្ថាន និងហាមបង្ហូរវត្ថុធាតុ សារធាតុពុល ឬ បង្កសកម្មភាពផ្សេងៗ ដូចមានចែងក្នុងមាត្រា២២ នៃច្បាប់នេះ។

<u>មាត្រា៥៨៖</u> ការនាំចូលពូជវារីសត្វ ឬវារីរុក្ខជាតិគ្រប់ប្រភេទពីបរទេសក្នុងគោលបំណងធ្វើវារីវប្បកម្មអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការអនុញ្ញាតពីប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល បន្ទាប់ពីបានពិនិត្យគុណភាព និងវាយតម្លៃលើគំរូសំណាកដោយមន្ទីរពិសោធន៍របស់រដ្ឋបាលជលផល។



Draft

**មាត្រា៥៩៖** ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិរួមគ្នាបង្កើតសហគមន៍នេសាទនៅតាមមូលដ្ឋានរបស់ខ្លួន ដោយឈរលើគោលការណ៍ស្ម័គ្រចិត្តដើម្បីចូលរួមគ្រប់គ្រង អភិរក្ស អភិវឌ្ឍ និងប្រើប្រាស់ធនធានជលផល ប្រកបដោយនិរន្តរភាព។ វិធានដើម្បីបង្កើត និងគ្រប់គ្រងសហគមន៍នេសាទត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦០៖** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិប្រគល់ផ្នែកណាមួយនៃដែននេសាទ ឲ្យទៅជាសហគមន៍ដែលរស់នៅក្នុង ឬក្បែរដែននេសាទក្រោមរូបភាពជាកន្លែងនេសាទសហគមន៍។

**មាត្រា៦៣៖** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិសោយកន្លែងនេសាទសហគមន៍ តាមការចាំបាច់ណាមួយសម្រាប់ផលប្រយោជន៍សាធារណៈ។

**មាត្រា៦៨៖** ការនាំចេញ ការនាំចូល ការទិញ ការលក់ ការដឹកជញ្ជូន ការកែច្នៃ និងការធ្វើសន្និធិប្រភេទផល ផលិតផលជលផលកំពុងរងគ្រោះថ្នាក់ អនុញ្ញាតបានចំពោះតែផលផលិតផលជលផល ដែលបានមកពីការ ធ្វើវារីវប្បកម្ម និង/ឬ ផ្អែកទៅតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា៦៤ មាត្រា៦៥ មាត្រា៦៦ និងមាត្រា៦៧ នៃច្បាប់នេះ និងអនុសញ្ញាសាយតេស។ ប្រភេទផលផលិតជលផលដែលកំពុងរងគ្រោះថ្នាក់ត្រូវកំណត់ ដោយអនុក្រឹត្យ។

**មាត្រា៦៩៖** -ហាមឃាត់:

១- ការទិញ ការលក់ ការកែច្នៃ ការធ្វើសន្និធិ និងការដឹកជញ្ជូនផល ផលិតផលជលផល ដែលបាន មកពីការធ្វើការនេសាទដោយខុសច្បាប់ ឬដោយប្រើឧបករណ៍នេសាទដោយខុសច្បាប់។

២- ការដឹកជញ្ជូនផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្មដោយគ្មានលិខិតអនុញ្ញាត ឬ ខុសខ្លឹមសារនៃលិខិតអនុញ្ញាតជាអាទិ៍ យថាប្រភេទ បរិមាណ សុពលភាព ចំណុចទីតាំង នៃទិស ដៅនិង/ឬផ្លូវ ដែលត្រូវឆ្លងកាត់ និងប្រភេទនៃមធ្យោបាយដឹកជញ្ជូន។

៣- ការដឹកជញ្ជូនឧបករណ៍នេសាទហាមឃាត់នៅក្នុងតំបន់គ្រប់គ្រងជលផល។

៤- ការដឹកជញ្ជូនផល ផលិតផលជលផលក្នុងរដូវបិទនេសាទដោយពុំមានភ្ជាប់លិខិតអនុញ្ញាតឲ្យ សន្និធិ ឬពុំបានកាត់ចេញនូវបរិមាណដឹកជញ្ជូនពីលិខិតអនុញ្ញាតឲ្យសន្និធិ។

## ៣.៦ ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ

១៣. ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័ត យល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០១ នាសម័យប្រជុំ ពេញអង្គ លើកទី៥ នីតិកាលទី១។ ហើយបានប្រកាសជាផ្លូវការឲ្យប្រើប្រាស់តាមព្រះរាជក្រម លេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលមានខ្លឹមសារដូចខាងក្រោម:

១៤. ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ការប្រើប្រាស់អណ្តូងរ៉ែ ព្រមទាំងរាល់សកម្មភាពទាំងឡាយដែលទាក់ទងទៅនឹងប្រតិបត្តិការធនធានរ៉ែ នៅព្រះរាជាណាចក្រកម្ពុជា។ លើកលែងតែប្រតិបត្តិការប្រេងកាត និងឧស្ម័នត្រូវស្ថិតនៅក្រោមច្បាប់មួយដោយឡែក។

១៥. ពាក់ព័ន្ធទៅនឹងកិច្ចការពារបរិស្ថាន ត្រង់មាត្រា២១ ជំពូកទី៥នៃច្បាប់នេះបានបញ្ជាក់ថា៖

- ការពារបរិស្ថានដូចមានលំអិតក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន ផែនការគ្រប់គ្រងបរិស្ថាន ផែនការលុបអណ្តូងរ៉ែនិងការធានាផ្នែកហិរញ្ញវត្ថុ។
- ធានាការពារសុខភាព និងសុវត្ថិភាពពលករដែលនឹងលំអិតក្នុងកម្មវិធីផែនការអណ្តូងរ៉ែ កម្មវិធីសុខភាពនិងសុវត្ថិភាពក្នុងអណ្តូងរ៉ែ រាប់បញ្ចូលទាំងការការពារគ្រោះថ្នាក់ បែបបទរាយការណ៍ស្តីពីគ្រោះថ្នាក់នេះ។
- ការពារសុវត្ថិភាពដល់សាធារណជន នៅក្នុងនិងជុំវិញតំបន់អណ្តូងរ៉ែ ដែលនឹងលំអិតក្នុងផែនការអណ្តូងរ៉ែ។
- ធ្វើការអប់រំ បណ្តុះបណ្តាលនិងផ្តល់ការងារដល់ប្រជាពលរដ្ឋខ្មែរ ដែលនឹងលំអិតក្នុងកម្មវិធីផ្តល់ការងារអប់រំបណ្តុះបណ្តាល។

## ៣.៧ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា

១៦. ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុម័តដោយរដ្ឋសភាជាតិកាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី២ និងប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧។ មាត្រាដែលពាក់ព័ន្ធនឹងការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៃគំរោងវិនិយោគនេះមានដូចខាងក្រោមៈ

<u>មាត្រា១៖</u> ច្បាប់នេះមានគោលដៅជំរុញឲ្យមានការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធិភាព និងនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីសំរេចបាននូវការងារអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងសុខមាលភាពរបស់ប្រជាពលរដ្ឋ។ ច្បាប់នេះកំណត់អំពីៈ

- សិទ្ធិ និងកាតព្វកិច្ចនៃអ្នកប្រើប្រាស់ទឹក
- គោលការណ៍គ្រឹះសំខាន់ៗ សំរាប់ការគ្រប់គ្រងធនធានទឹក
- ការចូលរួមរបស់សហគមន៍អ្នកប្រើប្រាស់ទឹកក្នុងការអភិវឌ្ឍន៍ធនធានទឹកប្រកបដោយនិរន្តរភាព។

<u>មាត្រា៣៖</u> ទឹក និងធនធានទឹក ជាសម្បត្តិរបស់រដ្ឋ។

<u>មាត្រា១១៖</u> បុគ្គលគ្រប់រូបមានសិទ្ធិប្រើប្រាស់ធនធានទឹកក្នុងបរិមាណមួយ មិនលើសពីសេចក្តីត្រូវការចាំបាច់ជាមូលដ្ឋានសម្រាប់ការហូបចុក បោកគក់ ងូត និងតម្រូវការផ្សេងៗ រួមមានការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ការស្រោចស្រពសួនច្បារ និងដំណាំ ដោយចៀសវាងមិនឲ្យមានការប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់អ្នកដទៃ។ តម្រូវការខាងលើនេះ មិនតម្រូវឲ្យសុំអាជ្ញាប័ណ្ណទឹកឡើយ។

<u>មាត្រា១២៖</u> ការបង្វែរទឹក ការយកទឹក ការប្រើប្រាស់ធនធានទឹក ក្នុងគោលបំណងកសិកម្ម ឬឧស្សាហកម្មលើសពីកំរិតដែលមានចែងក្នុងមាត្រា១១ និងសំណង់ការងារទឹកដែលពាក់ព័ន្ធ តម្រូវឲ្យមានការសុំអាជ្ញាប័ណ្ណទឹក ឬលិខិតអនុញ្ញាត។ បែបបទនៃការសុំនេះ និងមានចែងនៅក្នុងអនុក្រឹត្យ។ ការយកខ្សាច់ដី ឬគ្រួសប្រេងកាត និងឧស្ម័នពីបាត ច្រាំង ឆ្នេរសមុទ្រ ឆ្នេរទន្លេ ស្ទឹង ព្រែក អូរ បឹងបួ តម្រូវឲ្យមានការសុំអាជ្ញាប័ណ្ណ

ទឹក។ បែបបទបច្ចេកទេសជលសាស្ត្រដែលពាក់ពន្ធ័នឹងការងារនេះ នឹងមានចែងលំអិតនៅក្នុងអនុក្រឹត្យ។ ការលុបទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ អាងទឹក និងអាងធម្មជាតិ តម្រូវឲ្យមានការសុំអាជ្ញាប័ណ្ណទឹក ឬលិខិតអនុញ្ញាត។ បែបបទនៃការសុំនេះ នឹងមានចែងនៅក្នុងអនុក្រឹត្យ។ ការសាងសង់ស្ពានតូច ធំ កាត់ទន្លេ ស្ទឹង កំពង់ផែ ឬសំណង់អាគារតូច ធំលើច្រាំង និង ឆ្នេរតម្រូវឲ្យមានការឯកភាពផ្នែកបច្ចេកទេសជាមុនពីក្រសួងធនធានទឹក និងឧតុនិយម។ ការបង្វែទឹកពីប្រភពដើមចេញពីទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការអនុញ្ញាត និងយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជា ដោយមានការអនុម័តយល់ព្រមពីស្ថាប័ននីតិបញ្ញត្តិ។

<u>មាត្រា១៤៖</u> មុនពេលផ្តល់អាជ្ញាប័ណ្ណទឹកដល់បុគ្គលណាមួយ ក្រសួងធនធានទឹក និងឧតុនិយម ត្រូវពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានលើការប្រើប្រាស់ទឹក និងការសាងសង់សំណង់ការងារទឹកដែលបុគ្គលនោះស្នើឡើង។

<u>មាត្រា២២៖</u> រាល់ការបញ្ចេញចោល ការទុកចោល ឬការរក្សាទុកនូវសារធាតុពុលដែលអាចធ្វើឲ្យប៉ះពាល់ដល់គុណភាពទឹក និងអាចបង្កគ្រោះថ្នាក់ដល់មនុស្ស សត្វ និងរុក្ខជាតិ ត្រូវតែសុំអាជ្ញាប័ណ្ណទឹក ឬការអនុញ្ញាត។ ប្រភេទសារធាតុពុលដែលមានចែងខាងលើ និងស្តង់ដារបច្ចេកទេសនៃការបញ្ចេញទឹកសំណល់នឹងមានកំណត់ដោយអនុក្រឹត្យ។ រាល់កិច្ចដំណើរការក្នុងមាត្រានេះ ក្រសួងធនធានទឹក និងឧតុនិយម ត្រូវពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធនានា។

<u>មាត្រា២៣៖</u> ក្រសួងធនធានទឹក និងឧតុនិយម អាចប្រកាសទុកជាតំបន់អាសន្ន ឬជាតំបន់ហាមឃាត់ការប្រើប្រាស់ទឹកក្នុងករណីដែល៖

- ទឹកលើដី ឬទឹកក្រោមដីត្រូវបានប៉ះពាល់ផ្នែកបរិមាណ គុណភាព ឬគុណភាពអេកូឡូស៊ី។
- ទឹកលើទីជំរាលដែលកំពុងរងការគំរាមកំហែងដោយសកម្មភាពមនុស្ស ឬធម្មជាតិ។
- ទឹកដែលបណ្តាលឲ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ។

ដែនភូមិសាស្ត្រនៃតំបន់អាសន្ន ឬតំបន់ហាមឃាត់នោះ ត្រូវកំណត់តាមករណីនីមួយៗដោយប្រកាសរបស់ក្រសួងធនធានទឹក និងឧតុនិយម។

## ៣.៨ ច្បាប់ស្តីពីជីវសុវត្ថិភាព

**១៧.** ច្បាប់ស្តីពីជីវសុវត្ថិភាព ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយកាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៤ នីតិកាលទី២ និងប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០២០៨/០០៦ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ៖

<u>មាត្រា១៖</u> ច្បាប់នេះមានគោលបំណង៖ អនុវត្តគោលការណ៍ប្រុងប្រយ័ត្នស្តីពីជីវសុវត្ថិភាព ទប់ស្កាត់ ផលប៉ះពាល់អវិជ្ជមាន ទៅលើការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ដែលបណ្តាលមកពីការផលិត ការដឹកជញ្ជូនឆ្លងដែន ការអភិវឌ្ឍន៍ ការលើកដាក់ ការផ្ទេរ ការប្រើប្រាស់ ការស្តុកទុក និង

ការបញ្ចេញសារពាង្គកាយកែច្នៃរស់ ដែលបង្កើតឡើងដោយជីវបច្ចេកវិទ្យាទំនើប។ ជានាប្រសិទ្ធិភាពនៃការអភិរក្ស និងការប្រើប្រាស់ជីវៈចម្រុះដោយនិរន្តរភាព ព្រមទាំងយកចិត្តទុកដាក់ចំពោះហានិភ័យដល់សុខភាពមនុស្ស ធ្វើឲ្យមានតម្លាភាពក្នុងនីតិវិធីពិនិត្យ និងក្នុងការធ្វើសេចក្ដីសំរេចចំពោះសារពាង្គកាយកែច្នៃរស់ និងសកម្មភាពទាំងឡាយដែលទាក់ទងនឹងសារពាង្គកាយកែច្នៃរស់។ លើកកំពស់ការយល់ដឹងអំពីជីវបច្ចេកវិទ្យាទំនើបសំដៅទប់ស្កាត់ហានិភ័យពីការប្រើប្រាស់ និងការបញ្ចេញសារពាង្គកាយកែច្នៃរស់ទៅក្នុងបរិស្ថាននិងសុខភាពមនុស្ស។

<u>មាត្រា៣៖</u> ច្បាប់នេះអនុវត្តចំពោះការនាំចូល និងនាំចេញ ការប្រើប្រាស់ក្នុងព្រំដែនកំណត់ ការបញ្ចូលសារពាង្គកាយកែច្នៃរស់ទៅក្នុងបរិស្ថានដោយចេតនា និងការប្រើប្រាស់ផ្ទាល់ដើម្បីជាម្ហូបអាហារ ឬចំណីសត្វ ឬដើម្បីកែច្នៃរស់ ដែលអាចប៉ះពាល់ដល់ការអភិរក្ស និងការប្រើប្រាស់ជីវៈចម្រុះដោយនិរន្តរភាព ព្រមទាំងបញ្ហាសុខភាពមនុស្សផងដែរ។ ច្បាប់នេះនឹងមិនអនុវត្តចំពោះសារពាង្គកាយកែច្នៃរស់ សំរាប់ប្រើជាឱសថដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិដែលពាក់ព័ន្ធ។ សារពាង្គកាយកែច្នៃរស់ដែលគ្រាន់តែដឹកជញ្ជូនឆ្លងកាត់ តែពុំមានទិសដៅយកមកប្រើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ប្រភេទសារពាង្គកាយកែច្នៃរស់មួយចំនួនទៀត ដែលត្រូវបានលើកលែងដោយស្ថាប័នមានសមត្ថកិច្ច។ ផលិតផលសារពាង្គកាយកែច្នៃរស់មិនមានជីវិតឬ ក៏សមាសភាពនៃសារពាង្គកាយអជីវិតកែច្នៃសេនេទិច។

<u>មាត្រា៤៖</u> រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបានផ្ដល់ដំណឹងថាមានបំណងធ្វើសកម្មភាព ឬ ប្រតិបត្តិការទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ ដូចជា ការប្រើប្រាស់ក្នុងព្រំដែនកំណត់ការបញ្ចូលទៅក្នុងបរិស្ថានដោយចេតនា និងឬដើម្បីប្រើប្រាស់ដោយផ្ទាល់ធ្វើជាម្ហូបអាហារ ជាចំណីសត្វ ឬដើម្បីកែច្នៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានការឯកភាពជាមុនពីក្រសួងបរិស្ថាន មុននឹងសុំការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ។ សកម្មភាព ឬប្រតិបត្តិការណាមួយដែលពាក់ព័ន្ធនឹងសារពាង្គកាយកែច្នៃរស់ក្រោមបទបញ្ញត្តិនៃច្បាប់នេះ ត្រូវអនុវត្តស្របតាមស្តង់ដា និងវិធានការស្តីពីការគ្រប់គ្រង និងត្រួតពិនិត្យអំពីហានិភ័យដូចដែលបានកំណត់ក្នុងនីតិវិធីស្តីពីការវាយតំលៃហានិភ័យ ដូចបានចែងក្នុងជំពូកទី៥ ហើយនិងមានចែងលម្អិតដោយប្រកាសរបស់ក្រសួងបរិស្ថាន បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ។

<u>មាត្រា៦៖</u> ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធត្រូវត្រួតពិនិត្យរាល់សកម្មភាព និងប្រតិបត្តិការដែលពាក់ព័ន្ធនឹងសារពាង្គកាយកែច្នៃរស់ ដែលបានបញ្ញត្តិនៃច្បាប់នេះ។ ក្រសួងបរិស្ថាន ជាស្ថាប័នបង្គោលជាតិនិងជាស្ថាប័នមានសមត្ថកិច្ចក្នុងការអនុវត្តបទបញ្ញត្តិនៃច្បាប់នេះ។

<u>មាត្រា៧៖</u> ក្នុងការទទួលខុសត្រូវជាស្ថាប័នបង្គោលជាតិ ដូចបានចែងក្នុងមាត្រា៦ ខាងលើនេះ ក្រសួងបរិស្ថានត្រូវធ្វើជាស្ថាប័នទំនាក់ទំនងដំបូងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងលេខាធិការដ្ឋានអនុសញ្ញាជីវៈចម្រុះ។ ក្នុងតួនាទីជាស្ថាប័នមានសមត្ថកិច្ចរបស់ជាតិ ក្រសួងបរិស្ថានត្រូវទទួលខុសត្រូវក្នុងការបំពេញមុខងាររដ្ឋបាលដែលបានតំរូវសំរាប់អនុវត្តច្បាប់នេះ។ មុខងារទាំងនេះរួមមានការជូនដំណឹងទាន់ពេលវេលាទៅប្រទេសដទៃទៀត និងមណ្ឌលចែកចាយព័ត៌មានជីវសុវត្ថិភាព ព្រមទាំងអង្គការអន្តរជាតិដែលពាក់ព័ន្ធទាំងឡាយក្នុងករណីមានហេតុការណ៍ណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបណ្ដាលមកពីចលនាឆ្លងដែនណាមួយដោយអចេតនានៃសារពាង្គកាយកែច្នៃរស់។ មន្ត្រីរបស់ក្រសួងបរិស្ថានដែល

ត្រូវបានចាត់តាំងដោយសហការជាមួយមន្ត្រីជំនាញនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចធ្វើអធិការកិច្ច អាចប្រមូលយកគំរូតាង ឬវត្ថុតាងដើម្បីសំរួលដល់ការស៊ើបអង្កេតក្នុងទីតាំងដែលបាន ឬកំពុងមានសកម្មភាព ឬប្រតិបត្តិការទាក់ទងនឹងសារពាង្គកាយកែច្នៃរស់។

**មាត្រា១១៖** ការនាំចូលសារពាង្គកាយកែច្នៃរស់មកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបញ្ចូលទៅក្នុងបរិស្ថានដោយចេតនា ត្រូវបានតំរូវអោយមានការវាយតំលៃហានិភ័យ ព្រមទាំងមានការយល់ព្រមពីក្រសួងបរិស្ថានជាមុន មុននឹងស្នើសុំការអនុញ្ញាតនាំចូលពីស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ។ ម្ចាស់ស្នើត្រូវដាក់ពាក្យទៅក្រសួងបរិស្ថាន អំពីគោលបំណងនៃការនាំចូលរបស់ខ្លួន។

**មាត្រា១៩៖** អ្នកនាំចេញសារពាង្គកាយកែច្នៃរស់ពីព្រះរាជាណាចក្រកម្ពុជា ត្រូវមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីក្រសួងបរិស្ថាន ពីភាពត្រឹមត្រូវនៃរាល់ព័ត៌មានដែលខ្លួនបានផ្តល់ទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ត្រូវនាំចេញ។ លិខិតបញ្ជាក់នេះត្រូវភ្ជាប់ជាមួយនឹងលិខិតអនុញ្ញាតនាំចេញ និង/ឬឯកសារដទៃទៀតទាក់ទងនឹងការវេចខ្ចប់ ការលើកដាក់នាំចេញ។

**មាត្រា២១៖** ម្ចាស់សំណើត្រូវទទួលបន្ទុកក្នុងការវាយតំលៃហានិភ័យ និងទទួលរ៉ាប់រងលើចំណាយទាំងអស់សំរាប់ការវាយតំលៃនេះ។ នៅពេលបានទទួលលទ្ធផល នៃការវាយតំលៃហានិភ័យ និងឯកសារពាក់ព័ន្ធទាំងឡាយ ដែលបានតំរូវដោយច្បាប់នេះ ក្រសួងបរិស្ថាន នឹងផ្តល់ការឯកភាពជាគោលការណ៍ដោយមាន ឬគ្មានលក្ខខណ្ឌ ឬតំរូវអោយផ្តល់ព័ត៌មានបន្ថែម ឬបដិសេធមិនផ្តល់ការឯកភាព។

## ៣.៩ ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

១៨. ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តឲ្យប្រើប្រាស់នៅឆ្នាំ១៩៩៤ ហើយ ច្បាប់នេះបានធ្វើវិសោធនកម្មជាច្រើនលើក ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី២ ហើយព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិ នៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី១។ ច្បាប់នេះមានខ្លឹមសារដូចតទៅៈ

**មាត្រា១៖** ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា មានវិសាលភាពចំពោះរាល់គំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងកំណត់នីតិវិធីនៃការបង្កើតគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលធ្វើឡើងដោយបុគ្គលណាមួយ។ មានតែគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេ ដែលមានសិទ្ធិទទួលបាននូវផលប្រយោជន៍ ដែលស្ថិតក្នុងក្របខ័ណ្ឌនៃច្បាប់នេះ។

**មាត្រា២៖** គំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ គឺជាគំរោងវិនិយោគដែលទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ ហើយរាល់បុគ្គលដែលមានបំណងបង្កើតគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវដាក់សំណើវិនិយោគនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមទម្រង់ និងតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់នេះ និងអនុក្រឹត្យ។

## ៣-១០. ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម:

<u>មាត្រា២៩៖</u> រូបវន្តបុគ្គល ឬនីតិបុគ្គលដែលធ្វើការនាំចូលនាំចេញថ្នាំកសិកម្ម ត្រូវមានលិខិតអនុញ្ញាតដែលចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្នុងរាល់ប្រតិបត្តិការនៃការនាំចូលនាំចេញថ្នាំកសិកម្ម អ្នកនាំចូលនាំចេញត្រូវអនុវត្តលក្ខខណ្ឌនៃការតម្រូវបមាណីយដូចខាងក្រោម:

- ថ្នាំកសិកម្មត្រូវបានយល់ព្រមលើការចុះបញ្ជីរួចហើយ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ
- ត្រូវអនុវត្តបមាណីយសម្រាប់សំបកវេចខ្ចប់ ស្លាកសញ្ញាព័ត៌មាន ឬបរិយាយបណ្ណសម្រាប់ការណែនាំជាភាសាខ្មែរ ដែលត្រូវបានយល់ព្រមចុះបញ្ជី
- បញ្ជីឈ្មោះថ្នាំកសិកម្មដែលស្នើសុំនាំចូលនាំចេញ ត្រូវសម្គាល់ដោយលេខកូដប្រព័ន្ធសុខដុមនីយកម្មគយ
- ត្រូវអនុវត្តវិធានសុវត្ថិភាពក្នុងប្រតិបត្តិការនាំចូលនាំចេញថ្នាំកសិកម្មដែលតម្រូវដោយច្បាប់នេះ
- ត្រូវមានកំណត់ត្រាព័ត៌មានពាក់ព័ន្ធនឹងការនាំចូលនាំចេញថ្នាំកសិកម្ម
- ត្រូវជូនដំណឹងដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើការត្រួតពិនិត្យដើមគ្រានៅពេលនាំចូលនាំចេញ ឬនៅមុនពេលធ្វើការផ្គត់ផ្គង់ចែកចាយ
- ត្រូវភ្ជាប់ឯកសារបញ្ជាក់ក្រុមហ៊ុន ឬសាខាដែលចុះកិច្ចសន្យាទទួលយកការផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្មរបស់ខ្លួន
- ត្រូវអនុវត្តលក្ខខណ្ឌផ្សេងទៀតដែលតម្រូវដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

<u>មាត្រា៣០៖</u> រូបវន្តបុគ្គល ឬនីតិបុគ្គលដែលនាំចូលថ្នាំកសិកម្មក្នុងគោលបំណងប្រើប្រាស់ចុងក្រោយសម្រាប់ការប្រើប្រាស់ផ្ទាល់ក្នុងកសិដ្ឋានគ្រប់ប្រភេទទោះឯកជន ឬរដ្ឋ និងសម្រាប់តម្រូវការសាធារណៈជាក់លាក់ ឬសម្រាប់ការប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្ម ត្រូវសុំអនុញ្ញាតនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវបញ្ជាក់អំពីប្រភេទថ្នាំកសិកម្ម គោលបំណងប្រើប្រាស់ និងបរិមាណសមស្របដែលត្រូវស្នើសុំនាំចូល។

សំណើសុំនាំចូលសារធាតុគីមី ឬថ្នាំកសិកម្មប្រភេទគ្រោះថ្នាក់ខ្ពស់សម្រាប់គោលបំណងប្រើប្រាស់ចុងក្រោយជាក់លាក់ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ ត្រូវអនុលោមតាមនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុន។

<u>មាត្រា៣៧៖</u> រូបវន្តបុគ្គល ឬនីតិបុគ្គលដែលដឹកជញ្ជូនថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តលក្ខខណ្ឌចាំបាច់ដូចខាងក្រោម៖

១- ត្រូវប្រើមធ្យោបាយដឹកជញ្ជូន ឬមធ្យោបាយផ្ទុកដោយឡែក

២- សម្រាប់គោលបំណងនាំចេញ ត្រូវភ្ជាប់មកជាមួយនូវលិខិតអនុញ្ញាតនាំចូលនាំចេញ ដែលផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៣- សម្រាប់គោលបំណងផ្គត់ផ្គង់ចែកចាយ ត្រូវភ្ជាប់មកជាមួយនូវលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងឯកសារពាក់ព័ន្ធដែលកំណត់ច្បាស់លាស់នូវប្រភេទ បរិមាណនៃថ្នាំកសិកម្ម និងទីតាំង ឬគ្រឹះស្ថានដែលទទួលយកការផ្គត់ផ្គង់ចែកចាយ។

៤- ត្រូវដាក់តាំងលើមធ្យោបាយដឹកជញ្ជូន និងមធ្យោបាយផ្ទុកថ្នាំកសិកម្ម បង្ហាញនូវរូបសញ្ញា និងផ្លាកសញ្ញាដើម្បីសម្គាល់ ស្របតាមចំណាត់ថ្នាក់គ្រោះថ្នាក់នៃប្រភេទថ្នាំកសិកម្មដែលដឹកជញ្ជូន។

៥- ត្រូវបង្ហាញលិខិតអនុញ្ញាត ឬឯកសារពាក់ព័ន្ធដែលតម្រូវដោយច្បាប់នេះ ដើម្បីមន្ត្រីអធិការកិច្ចមានសមត្ថកិច្ច ធ្វើការត្រួតពិនិត្យ។

**<u>មាត្រា៤១</u>៖** រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រើប្រាស់ថ្នាំកសិកម្ម ត្រូវមានការយល់ដឹងដូចខាងក្រោមៈ

- ត្រូវជ្រើសរើសប្រភេទថ្នាំកសិកម្មសមស្របសម្រាប់ប្រភេទដំណាំ ឬប្រភេទផលិតផល និងប្រភេទសមាសភាពចង្រៃ
- ត្រូវប្រើប្រាស់តែប្រភេទថ្នាំកសិកម្ម ដែលមិនស្ថិតក្នុងចំណាត់ហាមឃាត់នៃបញ្ជីថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានប្រភពដើមផ្គត់ផ្គង់ចែកចាយស្របតាមច្បាប់នេះ មានស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ និងមានលេខបញ្ជីការផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅលើសំបកវេចខ្ចប់
- ត្រូវប្រើប្រាស់ថ្នាំកសិកម្មស្របតាមសេចក្តីណែនាំអំពីការប្រើប្រាស់ និងត្រូវអនុវត្តតាមរយៈពេលបញ្ឈប់ការប្រើប្រាស់មុនពេលពេលប្រមូលផល នៅលើស្លាកសញ្ញាព័ត៌មាននៃសំបកវេចខ្ចប់ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានយល់ព្រមលើការចុះបញ្ជី
- ត្រូវយល់ដឹងពីបច្ចេកទេសប្រើប្រាស់ថ្នាំកសិកម្ម និងត្រូវប្រើប្រាស់ឧបករណ៍សុវត្ថិភាពក្នុងពេលធ្វើប្រព្រឹត្តិកម្មលើសមាសភាពចង្រៃ
- ត្រូវយល់ដឹងពីវិធានសុវត្ថិភាពក្នុងការប្រើប្រាស់ថ្នាំកសិកម្ម ដើម្បីទប់ស្កាត់ភាពប្រឈមនឹងគ្រោះថ្នាក់ចំពោះខ្លួនឯង អ្នកដទៃ និងបរិស្ថាន។

**<u>មាត្រា៤២</u>៖** ក្រុមហ៊ុនថ្នាំកសិកម្ម ឬម្ចាស់កសិដ្ឋាន ត្រូវមានករណីយកិច្ចចំពោះកម្មករនិយោជិតរបស់ខ្លួនដូចខាងក្រោម៖

- ផ្តល់ការបណ្តុះបណ្តាលវិធានសុវត្ថិភាពក្នុងការគ្រប់គ្រង និងការប្រើប្រាស់ថ្នាំកសិកម្ម
- ផ្តល់ឧបករណ៍សុវត្ថិភាពដល់បុគ្គលិកប្រតិបត្តិការថ្នាំកសិកម្មផ្ទាល់
- កំណត់បទដ្ឋានសម្រាប់ឧបករណ៍ប្រើប្រាស់ថ្នាំកសិកម្ម និងឧបករណ៍ការពារសុវត្ថិភាព
- អនុវត្តកម្មវិធីត្រួតពិនិត្យ និងថែទាំសុខភាពជាប្រចាំ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រើប្រាស់ថ្នាំកសិកម្មគ្រប់ប្រភេទក្នុងកសិដ្ឋាន មានករណីយកិច្ចចូលរួមក្នុងគ្រប់សកម្មភាពអប់រំណែនាំស្តីពីវិធានសុវត្ថិភាពដោយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៤៣៖** ការបោះចោលសំណល់ប្រើប្រាស់ថ្នាំកសិកម្ម និងសំបកវេចខ្ចប់ថ្នាំកសិកម្មគ្រប់ប្រភេទ ត្រូវអនុវត្តតាមវិធានដូចខាងក្រោម៖

- មិនត្រូវបោះចោល កប់ ឬដុតបំផ្លាញសំណល់ពីការប្រើប្រាស់ថ្នាំកសិកម្ម នៅទីកន្លែងដែលគ្មានការអនុញ្ញាតពីអង្គភាពកសិកម្ម ឬអាជ្ញាធរមានសមត្ថកិច្ច
- មិនត្រូវប្រើប្រាស់ឡើងវិញនូវសំបកវេចខ្ចប់ថ្នាំកសិកម្ម ដើម្បីវេចខ្ចប់ផលិតផលដែលមិនមែនជាថ្នាំកសិកម្ម ជាពិសេសចំណីអាហារ ឬចំណីសត្វ។

គោលការណ៍ណែនាំស្តីពីវិធានសុវត្ថិភាពក្នុងការប្រើប្រាស់ថ្នាំកសិកម្ម ការបោះចោលសំណល់ពីការប្រើប្រាស់ថ្នាំកសិកម្ម និងសំបកវេចខ្ចប់ថ្នាំកសិកម្ម ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**មាត្រា៤៥៖** រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រើប្រាស់ថ្នាំកសិកម្ម ដែលបង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ ខូចខាតបរិស្ថាន ឬទ្រព្យសម្បត្តិសាធារណៈ ត្រូវជួសជុលការខូចខាត ឬត្រូវទទួលទណ្ឌកម្មតាមច្បាប់ជាធរមាន។

**មាត្រា៤៩៖** ត្រូវហាមឃាត់ចំពោះការប្រើប្រាស់ថ្នាំកសិកម្មគ្រប់ប្រភេទដូចខាងក្រោម៖

១.ការប្រើប្រាស់ថ្នាំកសិកម្មដែលស្ថិតក្នុងចំណាត់ថ្នាក់ហាមឃាត់នៃបញ្ជីថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីកម្ចាត់សមាសភាពចង្រៃគ្រប់ប្រភេទ។

២.ការប្រើប្រាស់ថ្នាំកសិកម្មលើដំណាំគ្រប់ប្រភេទ ឬលើស្មៅចំណីសត្វ មុនពេលប្រមូលផល មិនស្របតាមរយៈពេលបញ្ឈប់ការប្រើប្រាស់មុនប្រមូលផល ដែលកំណត់លើស្លាកសញ្ញាព័ត៌មានថ្នាំកសិកម្មនិងត្រូវបានយល់ព្រមក្នុងការចុះបញ្ជី។

៣.ការប្រើប្រាស់ថ្នាំកសិកម្ម ឬការធ្វើសេវាកម្មដោយប្រើថ្នាំកសិកម្មប្រភេទនិយ័តករការលូតលាស់ ឬប្រភេទជំរុញការលូតលាស់របស់រុក្ខជាតិ ឬដំណាំខុសប្រក្រតីលើសពីកំរិតប្រើប្រាស់ ឬលាយចម្រុះជាមួយនឹងសារធាតុគីមីគ្រោះថ្នាក់ដែលហាមឃាត់ ឬលាយជាមួយសារធាតុគីមីផ្សេងទៀតដោយផ្ទុយនឹងបទដ្ឋានបច្ចេកទេស ដែលបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន។

**មាត្រា៦៦៖** រូបវន្តបុគ្គល ឬនីតិបុគ្គលដែលនាំចូលជីគីមីកសិកម្មក្នុងគោលបំណងប្រើប្រាស់ចុងក្រោយសម្រាប់ការប្រើប្រាស់ផ្ទាល់ក្នុងកសិដ្ឋានគ្រប់ប្រភេទ ទោះជាឯកជន ឬរដ្ឋ និងសម្រាប់តម្រូវការសាធារណៈជាក់លាក់ ឬសម្រាប់ការប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្មផ្សេងៗទៀត ត្រូវស្នើសុំលិខិតអនុញ្ញាតនាំចូលនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវបញ្ជាក់អំពីប្រភេទជីកសិកម្ម គោលបំណងប្រើប្រាស់ និងបរិមាណសមស្របដែលត្រូវស្នើសុំនាំចូល។

**មាត្រា៧២៖**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវគ្រប់គ្រងចរាចរណ៍ និងការបោះចោលជីកសិកម្មខូចគុណភាព ឬជីកសិកម្មក្រៅបមាណីយ ដោយផ្តល់គោលការណ៍ណែនាំដល់ពាណិជ្ជករជីកសិកម្មក្នុងការទទួលខុសត្រូវចំពោះសកម្មភាពដែលពាក់ព័ន្ធ។

ជីកសិកម្មខូចគុណភាព ឬជីកសិកម្មក្រៅបមាណីយ ត្រូវធ្វើសន្និធិដាច់ដោយឡែក និងត្រូវដាក់សញ្ញាសម្គាល់លើសំបកវេចខ្ចប់ ដើម្បីការពារផលប្រយោជន៍របស់អ្នកប្រើប្រាស់ចុងក្រោយ។

ត្រូវហាមឃាត់ការធ្វើពាណិជ្ជកម្មជីកសិកម្មខូចគុណភាព ឬជីកសិកមុមក្រៅបមាណីយ ឬធ្វើការបោះចោលដោយបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន។

## ៣.១១ អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

១៩. អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន បានអនុម័តនៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩។ អនុក្រឹត្យមានគោលបំណងៈ

- ❖ កំណត់វាយតំលៃហេតុប៉ះពាល់បរិស្ថានលើគំរោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតំលៃដោយក្រសួងបរិស្ថានមុនដាក់ជូនរាជរដ្ឋាភិបាលសំរេច។
- ❖ កំណត់ប្រភេទ និងទំហំគំរោង សកម្មភាពដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន និងសាធារណៈដែលត្រូវវាយតំលៃហេតុប៉ះពាល់បរិស្ថាន។
- ❖ បំផុសឲ្យមានការចូលរួមពីសាធារណៈជន ក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណាក្នុងកិច្ចដំណើរអនុវត្តគំរោង។

២០. យោងតាមឧបសម្ព័ន្ធនៃអនុក្រឹត្យនេះផងដែរ ក៏មានការចាត់ថ្នាក់ពីប្រភេទគំរោងដែលទាក់ទងទៅនឹងវិស័យកសិកម្ម ដែលទាមទារឲ្យម្ចាស់គំរោងរៀបចំរបាយការណ៍ IEIA ឬ EIA លើគំរោងដីសម្បទានក្នុងការអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្ម។

## ៣.១២ អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក

២១. អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹកបានអនុម័តនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩។ អនុក្រឹត្យនេះៈ

- ❖ មានគោលដៅកំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការការពារសុខភាពមនុស្ស និង ការអភិរក្សជីវៈចម្រុះ។
- ❖ មានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយណា ដែលបង្កឲ្យមានការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ។
- ❖ ពាក់ព័ន្ធទៅនឹងអនុក្រឹត្យនេះផងដែរ មានភ្ជាប់ជូននូវឧបសម្ព័ន្ធចំនួន៥ ដើម្បីការពារការបំពុលទឹកសាធារណៈ ក៏ដូចជាការអភិរក្សជីវៈចម្រុះ និងសុខភាពមនុស្ស។
  - **ឧបសម្ព័ន្ធ១៖** ប្រភេទសារជាតុប្រកបដោយគ្រោះថ្នាក់
  - **ឧបសម្ព័ន្ធ២៖** កំរិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវពីប្រភពបំពុលចូលទៅក្នុងតំបន់ទឹកសាធារណៈឬទៅក្នុងប្រព័ន្ធបណ្តាញលូ។
  - **ឧបសម្ព័ន្ធ៣៖** ប្រភេទនៃប្រភពបំពុលដែលតំរូវឲ្យមានការសុំអនុញ្ញាត ពីក្រសួងបរិស្ថាន មុននឹងបញ្ចេញចោលនូវសំណល់រាវរបស់ខ្លួន ឬដឹកទៅទីដទៃ។

Draft

- **ឧបសម្ព័ន្ធ៤៖** កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈសំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹក។
- **ឧបសម្ព័ន្ធ៥៖** កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈសំរាប់ការពារសុខភាពសាធារណៈ។

## ៣.១៣ អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង

២២. អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹង បានអនុម័តនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ អនុក្រឹត្យនេះ៖

- ❖ មានគោលដៅកំណត់ការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេសសមស្រប និងប្រកបដោយសុវត្ថិភាពសំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និង ការអភិរក្សជីវៈចម្រុះ។
- ❖ មានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចេញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់។
- ❖ ពាក់ព័ន្ធទៅនឹងអនុក្រឹត្យនេះ មានភ្ជាប់ជាមួយនូវឧបសម្ព័ន្ធដែលកំណត់ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់។

## ៣.១៤ អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង

២៣. អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេងបានអនុម័តនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០។ អនុក្រឹត្យនេះមានគោលដៅ៖

- ❖ កំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង ដើម្បីទប់ស្កាត់ និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់ និងសំលេងក្នុងបរិយាកាស សំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ។
- ❖ មានវិសាលភាពអនុវត្ត និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័ត និងអចល័តទាំងឡាយណាដែលបង្កឲ្យមានការបំពុលខ្យល់ និងការរំខានដោយសំលេងនៅក្នុងបរិយាកាស។
- ❖ ពាក់ព័ន្ធទៅនឹងអនុក្រឹត្យនេះ មានភ្ជាប់ជូននូវឧបសម្ព័ន្ធចំនួន៨ ដើម្បីការការពារបំពុលខ្យល់ និងការរំខានដោយសំលេង ពីប្រភពបំពុលចល័ត និងអចល័តដើម្បីការពារសុខភាពមនុស្ស។
    - **ឧបសម្ព័ន្ធ១៖** កំរិតកំណត់ស្តង់ដារគុណភាពខ្យល់
    - **ឧបសម្ព័ន្ធ២៖** កំរិតកំណត់ស្តង់ដារជាអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ដែលអនុញ្ញាតឲ្យមាននៅក្នុងខ្យល់។
    - **ឧបសម្ព័ន្ធ៣៖** កំរិតកំណត់ស្តង់ដារជាអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញពីប្រភពអចល័តចូលទៅក្នុងបរិយាកាស។
    - **ឧបសម្ព័ន្ធ៤៖** កំរិតកំណត់ស្តង់ដារនៃការបញ្ចេញឧស្ម័នពីប្រភពអចល័ត។
    - **ឧបសម្ព័ន្ធ៥៖** កំរិតកំណត់ស្តង់ដារជាអតិបរមាដែលអនុញ្ញាតបញ្ចេញសំលេងនៅលើផ្លូវសាធារណៈពីប្រភពយានយន្ត។

- **ឧបសម្ព័ន្ធ៦៖** កំរិតកំណត់ស្តង់ដារជាសំលេងអតិបរមាដែលអនុញ្ញាតនៅតំបន់សាធារណៈ និងតំបន់លំនៅដ្ឋាន។
- **ឧបសម្ព័ន្ធ៧៖** កំរិតកំណត់ស្តង់ដារសំរាប់ត្រួតពិនិត្យសំលេងក្នុងទីតាំងរោងជាងរោងចក្រឧស្សាហកម្ម។
- **ឧបសម្ព័ន្ធ៨៖** កំរិតកំណត់ស្តង់ដារ ជាតិស្ពាន់ធ័រ សំណ បង់សែន និងអ៊ីដ្រូកាបួប្រហើរដែលអនុញ្ញាតឲ្យមាននៅក្នុងប្រេងឥន្ធនៈ និងធ្យូងថ្ម។

## ៣.១៥ អនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច

២៤. អនុក្រឹត្យលេខ ១៤៦ អនក្រ.បក ស្តីពីសម្បទានដីសេដ្ឋកិច្ចបានអនុម័តនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០០៥ ដោយរាជរដ្ឋាភិបាលកម្ពុជា។ អនុក្រឹត្យនេះគោលដៅកំណត់លក្ខណៈវិនិច្ឆ័យ នីតិវិធី យន្តការ និងការរៀបចំស្ថាប័នសំរាប់ការផ្តួចផ្តើម និងការផ្តល់ដីសម្បទានសេដ្ឋកិច្ច ដែលបានចុះកិច្ចសន្យាមុនពេល ដែលអនុក្រឹត្យនេះចូលជាធរមាន ស្របតាមការកំណត់នៃច្បាប់ភូមិបាល ឆ្នាំ២០០១។ ជាមួយគ្នានេះដែរ អនុក្រឹត្យនេះបានតំរូវឲ្យម្ចាស់គំរោងរៀបចំការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង សំរាប់គំរោងសម្បទានដីសេដ្ឋកិច្ច។ ក្នុងករណីណាដែលការវាយតំលៃដំបូងបានបង្ហាញឲ្យឃើញថា មានហេតុប៉ះពាល់បរិស្ថានអវិជ្ជមានមានកំរិតមធ្យមឬខ្លាំង ត្រូវរៀបចំការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ។

## ៣.១៦ អនុក្រឹត្យ និងលិខិតផ្សេងៗ នៃតំបន់ដីសម្បទាន

- លិខិតលេខ ១៤៣៧ កសក ចុះថ្ងៃទី ១៩ ខែមិនា ឆ្នាំ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីសំណើសុំដីសម្បទានចំនួន១០.០០០ហិកតា របស់ក្រុមហ៊ុន **ដូទីសាយហ្គន-ប៊ិញហឿក (អេស ប៊ី ខេ)** សម្រាប់វិនិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី និងការបង្កើតរោងចក្រកែច្នៃ ស្ថិតនៅឃុំថ្មី និងឃុំកន្ទួត ស្រុកក្រចេះ (បច្ចុប្បន្នស្រុកចិត្របុរី) ខេត្តក្រចេះ។
- លិខិតលេខ ៣៧៧ សជណ ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ ២០០៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីករណីសំណើសុំដីសម្បទានចំនួន ១០.០០០ហិកតា របស់ក្រុមហ៊ុន **ដូទីសាយហ្គន -ប៊ិញហឿក (អេស ប៊ី ខេ)** សម្រាប់វិនិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី និង បង្កើតរោងចក្រកែច្នៃស្ថិតនៅ ឃុំថ្មី និងឃុំកន្ទួត ស្រុកក្រចេះ (បច្ចុប្បន្នស្រុកចិត្របុរី) ខេត្តក្រចេះ។
- លិខិតលេខ ១៧០០ កសក ចុះថ្ងៃទី២៨ ខែមិនា ឆ្នាំ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីសំណើសុំសិទ្ធិប្រទានពីរាជរដ្ឋាភិបាល ដើម្បីចុះហត្ថលេខាលើកិច្ចសន្យាដីសម្បទានចំនួន ៦.៤៣៦ហិកតា សម្រាប់និវិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី និងបង្កើតរោងចក្រកែច្នៃស្ថិតនៅឃុំថ្មី និងឃុំកន្ទួត ស្រុកក្រចេះ (បច្ចុប្បន្នស្រុកចិត្របុរី) ខេត្តក្រចេះ របស់ក្រុមហ៊ុន **ដូទីសាយហ្គន-ប៊ិញហឿក (អេស ប៊ី ខេ)**។
- សិទ្ធិប្រទានលេខ៣២ សប្រទ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៧ របស់រាជរដ្ឋាភិបាល ស្តីពីការប្រគល់សិទ្ធិពេញសមត្ថភាពជូនឯកឧត្តម **ចន្ទ័ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង

នេសាទ ដើម្បីចុះហត្ថលេខាលើកិច្ចសន្យាដីសម្បទានចំនួន ៦.៤៣៦ហិកតា សម្រាប់វិនិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី និងបង្កើតរោងចក្រកែច្នៃ ជាមួយក្រុមហ៊ុន **ដូទីសាយហ្គន -ប៊ិញហឿក (អេស ប៊ី ខេ)** ។

- កិច្ចសន្យាចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០៧ ស្តីពី ការវិនិយោគដាំកៅស៊ូ ដំឡូងមី ស្វាយចន្ទី និងបង្កើតរោងចក្រកែច្នៃ រវាងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងក្រុមហ៊ុន **ដូទីសាយហ្គន-ប៊ិញហឿក** (អេស ប៊ី ខេ) ។

## ៣.១៧ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា

## ចតុកោណទី១. ការលើកស្ទួយវិស័យកសិកម្ម

២៥. វិស័យកសិកម្មនៅតែមានតួនាទីសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច, ធានាសមធម៌, ធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ។ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល គឺការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជាតាមអភិក្រម និងក្នុងវិសាលភាព និងល្បឿនថ្មីដើម្បីប្រែក្លាយវិស័យនេះ ពីដំណាក់កាលនៃការអភិវឌ្ឍន៍តាមបែបវិបុលកម្ម (បើកទូលាយ) ពោលគឺពឹងផ្អែកសំខាន់លើធនធានមានស្រាប់ (ធនធានដី និងធនធានធម្មជាតិផ្សេងទៀត) និងពឹងផ្អែកលើការប្រើប្រាស់ធាតុចូលកសិកម្មតាមបែបប្រពៃណីឈានទៅរកដំណាក់កាលថ្មីដែលផ្តោតលើផលិតកម្មតាមបែបប្រពលវប្បកម្ម (ស៊ីជម្រៅ) ពោលគឺ ពឹងផ្អែកជាសំខាន់លើការប្រើប្រាស់បច្ចេកទេស, បច្ចេកវិទ្យាថ្មី, ការស្រាវជ្រាវ និងការអភិវឌ្ឍន៍, យន្តូបនីយកម្ម ព្រមទាំងការបង្កើនសមត្ថភាពស្រោចស្រព ដើម្បីលើកកំពស់ផលិតភាព, ពិពិធកាវូបនីយកម្មមុខដំណាំ និងផលិតផលកសិកម្មផ្សេងទៀត រួមទាំងការចិញ្ចឹមសត្វ និងវារីវប្បកម្មផង ដោយគិតគូរផងដែរអំពីភាពចាំបាច់ក្នុងការគ្រប់គ្រងដីធ្លីប្រកបដោយប្រសិទ្ធភាព និងការធានាចីរភាពបរិស្ថាន និងធនធានធម្មជាតិ។ ទន្ទឹមនេះ ការបន្តជំរុញការធ្វើពាណិជ្ជូបនីយកម្ម និងការអភិវឌ្ឍន៍វិស័យកសិកម្ម ឧស្សាហកម្ម នឹងជួយបង្កើនចំណូលជូនប្រជាកសិករ។

- **មុំទី១. ការលើកកម្ពស់ផលិតភាព, ពិពិធកាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម**

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៤ គឺការលើកកម្ពស់ផលិតភាព និងការធ្វើពិពិធកាវូបនីយកម្ម តាមរយៈការពង្រីកសមត្ថភាពផលិតលើផ្ទៃដីដែលមានស្រាប់ ដោយផ្តោតលើអន្តរាគមន៍ប្រទាក់ក្រឡាក្នុងវិស័យពាក់ព័ន្ធ ដូចជាការប្រើប្រាស់ធាតុចូលកសិកម្មតាមបច្ចេកទេស, ការស្រាវជ្រាវ និងការអភិវឌ្ឍន៍, ប្រព័ន្ធសេវាបច្ចេកទេសកសិកម្ម, ការសាងសង់ និងថែទាំហេដ្ឋារចនាសម្ព័ន្ធជនបទ, ការផ្តល់ឥណទានជនបទ និងមីក្រូហិរញ្ញវត្ថុ, ការពង្រីកទីផ្សារកសិកម្ម, ការរៀបចំសហគមន៍កសិកម្ម និងការគ្រប់គ្រងដីធ្លីកសិកម្ម។

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងឡាយ រាជរដ្ឋាភិបាលនីតិកាលទី៥ នឹងខិតខំរក្សាកំណើនក្នុងវិស័យកសិកម្មនេះ ឲ្យបានក្នុងរង្វង់ ៥% ក្នុងមួយឆ្នាំ ដោយបន្តលើកកម្ពស់ផលិតភាព, ធ្វើពិពិធកាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម។

- **មុំទី២. ការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្ម**

រាជរដ្ឋាភិបាលនីតិកាលទី៤ បានផ្តោតការយកចិត្តទុកដាក់ទៅលើការកែទម្រង់ជលផល ក្នុងគោលដៅបំពេញតម្រូវការអាហារូបត្ថម្ភ និងថែរក្សាធនធានមច្ឆជាតិឲ្យបានគង់វង្ស តាមរយៈការរៀបចំសហគមន៍នេសាទ, ការកែទម្រង់ការគ្រប់គ្រងឡូត៍នេសាទ, ការអភិរក្សព្រៃលិចទឹក, ការប្រយុទ្ធនិងការនេសាទខុសច្បាប់ និងការបំផុសវារីវប្បកម្ម។

រាជរដ្ឋាភិបាលនីតិកាលទី៥ មានគោលដៅជំរុញលើកកម្ពស់ចលនាសត្វ និងវារីវប្បកម្ម ឲ្យកាន់តែទូលំទូលាយថែមទៀតតាមរយៈការបង្កើតក្របខណ្ឌគោលនយោបាយដោយផ្អែកលើគោលការណ៍ខ្សែចង្វាក់តម្លៃ ដើម្បីដោះស្រាយជាកញ្ចប់នូវបញ្ហាជាឧបសគ្គដល់ការអភិវឌ្ឍន៍វិស័យទាំងនេះ ដោយគិតគូរផងដែរដល់បញ្ហាសុវត្ថិភាព ចំណីអាហារ និងកិច្ចដំណើរការទីផ្សារ ពិសេសអនាម័យ និងភូតគាមអនាម័យ ទន្ទឹមនឹងការបន្តអនុវត្តវិធានការមុតស្រួចនានា សំដៅធានារក្សាជីវភាពនៃធនធានជលផល ទាំងក្នុងដែនទឹកសាប និងសមុទ្រ។

- **មុំទី៣. ការកែទម្រង់ដីធ្លី, ការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម**

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺការបន្តធ្វើកំណែទម្រង់ដីធ្លី ដើម្បីពង្រឹងការប្រព័ន្ធគ្រប់គ្រង, បែងចែក និងប្រើប្រាស់ដីធ្លី, ធានាសុវត្ថិភាពកម្មសិទ្ធដី, លុបបំបាត់ភាពអនាធិបតេយ្យក្នុងការកាន់ដីដោយខុសច្បាប់ និងទប់ស្កាត់ការប្រមូលដីទុកដោយមិនបានប្រើប្រាស់ និងមិនផលិត ព្រមទាំងបន្តបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ដែលត្រូវបានកំណត់ជាគោលដៅទី៩ នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។

រាជរដ្ឋាភិបាលនីតិកាលទី៥ នឹងបន្តអនុវត្តកាន់តែសកម្មនិងស៊ីជម្រៅថែមទៀត នូវការកែទម្រង់ដីធ្លីដោយផ្តោតលើការពង្រឹងការគ្រប់គ្រងម្រេចគោលដៅជាតិ ក្នុងការកាត់បន្ថយភាពក្រីក្រ, ការធានាសន្តិសុខស្បៀង, ការការពារបរិស្ថាន និងធនធានធម្មជាតិ និងការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ក្នុងបរិការណ៍នៃសេដ្ឋកិច្ចទីផ្សារ។

- **មុំទី៤. ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព**

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ បានផ្តោតលើការគ្រប់គ្រង និងអភិរក្សធនធានព្រៃឈើ និងជលផល ដើម្បីធានាចីរភាពនៃកំណើនសេដ្ឋកិច្ចជាតិ និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជននៅតាមជនបទតាមរយៈការជំរុញអនុវត្តកម្មវិធីព្រៃសហគមន៍, ការត្រួតពិនិត្យតាមដានការធ្វើអាជីវកម្មព្រៃឈើ ការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ និងការអនុវត្តវិធានការម៉ឺងម៉ាត់ចំពោះបទល្មើសព្រៃឈើ, ការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងព្រៃបំរុង, ការអនុវត្តស៊ីជម្រៅនូវការកែទម្រង់ឡូត៍នេសាទ និងជលផល។

ក្នុងនីតិកាលទី៥នេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹង និងពង្រីកថែមទៀតនូវការគ្រប់គ្រងធនធានធម្មជាតិ សំដៅរក្សា «តុល្យភាពរវាងការអភិវឌ្ឍន៍ និងការអភិរក្ស» ពិសេសលើកកម្ពស់វិភាគទាននៃធនធានធម្មជាតិ ចំពោះការអភិវឌ្ឍន៍វិស័យកសិកម្ម តាមរយៈ (១)- ការធានាគម្របបៃតង, ការអភិរក្សព្រៃឈើ និងសត្វព្រៃ, (២)ការធានាចីរភាពនៃធនធានជលផល, និង (៣)- ការរក្សាចីរភាពប្រព័ន្ធអេកូឡូស៊ី ដើម្បីធានាគុណភាពដី និងចីរភាពនៃប្រភពទឹក ដោយផ្តោតលើការការពារជីវចម្រុះ, តំបន់ដីសើម និងតំបន់ឆ្នេរ។

ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលនឹងប្រកាន់យកអភិក្រម ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងប្រទាក់ក្រឡាគ្នា សំដៅលើកកម្ពស់ប្រសិទ្ធភាព និងសមធម៌ក្នុងការប្រើប្រាស់ធនធានធម្មជាតិ តាមរយៈ (១)- ការកំណត់ច្បាស់លាស់នូវកម្មសិទ្ធលើធនធានធម្មជាតិ (២)- ការពង្រឹងប្រព័ន្ធលើកទឹកចិត្តត្រឹមត្រូវក្នុងការងារអភិរក្សធនធានធម្មជាតិ និងការផ្តល់សិទ្ធិអំណាចដល់អាជ្ញាធរថ្នាក់ក្រោមជាតិ, សហគមន៍ និងប្រជាជនម្នាក់ៗក្នុងការចូលរួមអភិរក្សធនធានធម្មជាតិ ដោយផ្តោតលើការបណ្តុះបណ្តាល, ការផ្តល់ព័ត៌មាន ព្រមទាំងការពង្រឹងមូលដ្ឋានសង្គម, គណនេយ្យភាព និងតម្លាភាពនៃស្ថាប័ន និង(៣)- ការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយគូអង្គអភិរក្សពាក់ព័ន្ធ ក្នុងក្របខណ្ឌកំណើនបៃតង និងការប្រែប្រួលអាកាសធាតុ។

## ចតុកោណទី២. ការអភិវឌ្ឍន៍វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

២៦. ការអភិវឌ្ឍន៍ និងទំនើបកម្មវិស័យហេដ្ឋារចនាសម្ព័ន្ធ គឺជាកត្តាដ៏សំខាន់សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច, បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ចព្រមទាំងពង្រីកភាពប្រកួតប្រជែង និងជំរុញពិពិធកម្មសេដ្ឋកិច្ចកម្ពុជាពិសេសសម្រាប់កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ក្នុងន័យនេះ ដើម្បីឆ្លើយតបទៅនឹងដំនាក់កាលថ្មីនៃការអភិវឌ្ឍន៍សម្រាប់រយៈពេលវែងខាងមុខ រាជរដ្ឋាភិបាលនឹងរៀបចំនូវផែនការមេនៃការតភ្ជាប់មួយ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ទាំងផ្នែករឹង ទាំងផ្នែកទន់ ដែលគ្របដណ្តប់លើវិស័យគមនាគមន៍ដឹកជញ្ជូន, វិស័យថាមពលអគ្គីសនី ព្រមទាំងវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ទន្ទឹមនឹងការបន្តជំរុញអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ និងវិស័យទឹកស្អាត។ ជាមួយនេះ រាជរដ្ឋាភិបាលនឹងបង្កើនការយកចិត្តទុកដាក់លើការរៀបចំហេដ្ឋារចនាសម្ព័ន្ធទីក្រុង។ កិច្ចការទាំងអស់នេះ នឹងត្រូវបានធ្វើដោយជានាសង្គតិភាពជាមួយនឹងក្របខណ្ឌនៃការរៀបចំដែនដី និងនគរូបនីយកម្ម។

### - មុំទី១. វិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធទីក្រុង

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ជាអាទិ៍ ការបន្តសាងសង់ផ្លូវ, ការថែទាំផ្លូវ, ការពង្រឹងសមត្ថភាពកំពង់ផែ, ការស្តារ និងការអភិវឌ្ឍន៍វិស័យផ្លូវដែក, ការពង្រីកសេវាអាកាសយានដ្ឋាន និងការពង្រីកសុវត្ថិភាពហោះហើរ និងសុវត្ថិភាពចរាចរណ៍។ រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពល្អប្រសើរក្នុងការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ដើម្បីសមាហរណកម្មផ្ទៃក្នុងប្រទេស និងការតភ្ជាប់ទៅនឹងតំបន់។

ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការអភិវឌ្ឍន៍ក្នុងដំណាក់កាលថ្មី រាជរដ្ឋាភិបាលនីតិកាលទី៥ ដាក់ចេញនូវគោលដៅបន្តអភិវឌ្ឍបណ្តាញហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ដឹកជញ្ជូនគ្រប់ប្រភេទ រួមជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធទីក្រុង ឲ្យក្លាយទៅជាប្រព័ន្ធឡូជីស្ទីកមួយដ៏រស់រវើក, មានសុវត្ថិភាព និងមានប្រសិទ្ធភាព សំដៅរួមចំណែកលើកកម្ពស់ភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ ព្រមទាំងជួយលើកស្ទួយសុខុមាលភាពរបស់ប្រជាជន។

### - មុំទី២. ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺការជំរុញកសាងថែទាំ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ និងការផ្គត់ផ្គង់ទឹកស្អាត។

រាជរដ្ឋាភិបាលនីតិកាលទី៥ នឹងបន្តលើកកម្ពស់ការគ្រប់គ្រងធនធានទឹក និងការអភិវឌ្ឍន៍ប្រព័ន្ធជារាសាស្ត្រ, បង្កើនប្រសិទ្ធភាពនៃការថែទាំ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធជារាសាស្ត្រ, ជំរុញសមាហរណកម្មប្រព័ន្ធជារាសាស្ត្រជាមួយនឹងការអភិវឌ្ឍន៍អគ្គីសនី និងប្រព័ន្ធដឹកជញ្ជូន ព្រមទាំងលើកកម្ពស់ការអភិវឌ្ឍន៍ក្របខណ្ឌគតិយុត្ត, ស្ថាប័ន និងធនធានមនុស្ស។

- **មុំទី៣. ការអភិវឌ្ឍន៍វិស័យថាមពលអគ្គីសនី**

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺការបន្តពង្រីកវិសាលភាពនៃការផ្គត់ផ្គង់, ការចុះថ្លៃអគ្គីសនីឲ្យបានសមរម្យ និងការពង្រឹងយន្តការស្ថាប័ន និងសមត្ថភាពគ្រប់គ្រង។

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ក្នុងវិស័យថាមពលអគ្គីសនី គឺការបន្តពង្រឹងសមត្ថភាព និងសុវត្ថិភាពក្នុងការផ្គត់ផ្គង់ ព្រមទាំងការពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ ដើម្បីបង្កើនភាពប្រកួតប្រជែងសេដ្ឋកិច្ច, ទ្រទ្រង់កំណើនសេដ្ឋកិច្ចរយៈពេលវែង, ពង្រឹងសមត្ថភាពធានាសន្តិសុខថាមពលអគ្គីសនី និងលើកកម្ពស់ជីវភាពរបស់ប្រជាជន។

- **មុំទី៤. ការអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍**

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺជំរុញការអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ទំនើប និងប្រកបដោយគុណភាពតាមរយៈការពង្រឹងក្របខណ្ឌគតិយុត្ត, ការកសាងសមត្ថភាពស្ថាប័ន, ការធ្វើទំនើបកម្មមូលដ្ឋានសម្ភារៈបច្ចេកទេស, ការលើកស្ទួយការប្រកួតប្រជែង, ការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងរដ្ឋបាលអេឡិចត្រូនិច ព្រមទាំងការជំរុញសាងសង់ និងបង្កើនប្រសិទ្ធភាពនៃហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នង សម្រាប់វិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍។

ក្នុងគោលដៅត្រៀមរៀបចំមូលដ្ឋាន សម្រាប់ការឈានឡើងរបស់កម្ពុជាទៅកាន់ដំណាក់កាលថ្មីនៃការអភិវឌ្ឍន៍ ពិសេសការធានាភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុង «សេដ្ឋកិច្ចពុទ្ធិ» នាពេលអនាគត, រាជរដ្ឋាភិបាលនីតិកាលទី៥ នឹងបន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ឲ្យមានលក្ខណៈទំនើបទាន់សម័យ មានគុណភាពខ្ពស់ ស្របតាមស្តង់ដាអន្តរជាតិ, មានថ្លៃប្រកួតប្រជែង និងមានសេវាគ្របដណ្តប់នៅទូទាំងប្រទេស ដែលប្រជាជនទូទៅអាចប្រើប្រាស់បាន និងទទួលផលប្រយោជន៍គ្រប់ៗគ្នាពីសេវានេះ។

**ចតុកោណទី៣. ការអភិវឌ្ឍន៍វិស័យឯកជន និងការងារ**

**២៧.** រាជរដ្ឋាភិបាលបានកំណត់ថា «**វិស័យឯកជន គឺជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច**»។ ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការនៃការអភិវឌ្ឍន៍ក្នុងដំណាក់កាលថ្មី រាជរដ្ឋាភិបាលនឹងបន្តជំរុញអភិវឌ្ឍវិស័យឯកជនតាមរយៈវិធានការជាកញ្ចប់ និងគ្រប់ជ្រុងជ្រោយ សំដៅរៀបចំ និងកែលម្អគោលនយោបាយពាក់ព័ន្ធផ្សេងៗទៀត រួមទាំងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងធនាគារ និងទីផ្សារការងារផង។ ក្នុងកិច្ចដំណើរការនេះ រាជរដ្ឋាភិបាលនឹងដាក់ចេញនូវ « **គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម** » ដែលមានតួនាទីស្នូលក្នុងការនាំសេដ្ឋកិច្ចកម្ពុជាឈានឡើងកាន់កម្ពស់ថ្មីមួយ ក្នុងខ្សែចង្វាក់នៃតម្លៃបន្ថែមក្នុងតំបន់ និងសកលលោក។

- **មុំទី១. ការពង្រឹងវិស័យឯកជន និងការជំរុញការវិនិយោគ និងធុរកិច្ច**



Draft

រាជរដ្ឋាភិបាលនីតិកាលទី៥ ដាក់ចេញនូវគោលដៅជាយុទ្ធសាស្ត្រពីរ គឺ៖ (១)- ការបន្តជំរុញអភិវឌ្ឍវិស័យឯកជនឲ្យកាន់តែមានភាពរស់រវើក និងមានជីវភាពខ្លាំងថែមទៀត ក្នុងតួនាទីជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច និង(២)- ការប្រែក្លាយកម្ពុជាឲ្យទៅជាគោលដៅវិនិយោគប្រកបដោយភាពទាក់ទាញ និងភាពប្រកួតប្រជែងនៅក្នុងតំបន់ ពិសេសក្នុងក្របខណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន។

- **មុំទី២. ការអភិវឌ្ឍន៍ឧស្សាហកម្ម និងសហគ្រាសធុនតូច និងមធ្យម**

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម ពិសេសការពង្រឹងបរិស្ថានធុរកិច្ច តាមរយៈការកែលម្អក្របខណ្ឌគតិយុត្ត, លើកស្ទួយនវានុវត្តន៍ និងបច្ចេកវិទ្យា, ការលើកកម្ពស់លទ្ធភាពទទួលហិរញ្ញប្បទាន និងការពង្រឹង និងពង្រីកសេវាគាំទ្រផ្សេងៗទៀត ព្រមទាំងការធ្វើសមាហរណកម្មសហគ្រាសធុនតូច និងមធ្យមទៅក្នុងខ្សែចង្វាក់តម្លៃជាសកល។

ក្នុងនីតិកាលទី៥ គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺការបន្តធ្វើពិពិធកម្មមូលដ្ឋានឧស្សាហកម្ម តាមរយៈការជំរុញលើកទឹកចិត្តវិនិយោគក្នុងវិស័យឧស្សាហកម្មថ្មីៗទំនើប ដែលមានតម្លៃបន្ថែមខ្ពស់, មានភាពច្នៃប្រឌិតរស់រវើក និងមានសមត្ថភាពប្រកួតប្រជែង ពិសេសឧស្សាហកម្មផ្គុំដំឡើង, ឧស្សាហកម្មអេឡិចត្រូនិច, ឧស្សាហកម្មគ្រឿងបន្លាស់, ឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម និងឧស្សាហកម្មកម្មន្តសាលផ្សេងទៀត, គួបផ្សំនឹងការបន្តជំរុញអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម រួមទាំងសិប្បកម្មផង ព្រមទាំងការរុញការអភិវឌ្ឍន៍ឧស្សាហកម្មឲ្យទៅដល់ទីជនបទ សំដៅរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច ក៏ដូចជាបង្កើតការងារ និងបង្កើនចំណូលជូនប្រជាជន។ បន្ថែមលើនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ផងដែរទៅលើការអភិវឌ្ឍន៍ និងការគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវខ្ពស់លើវិស័យឧស្សាហកម្មនីស្សារណកម្ម ដើម្បីប្រែក្លាយសក្តានុពលដែលមាននេះ ឲ្យក្លាយទៅជាប្រភពមួយទៀតនៃកំណើនសេដ្ឋកិច្ចកម្ពុជា។

- **មុំទី៣. ការអភិវឌ្ឍន៍ទីផ្សារការងារ**

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺការបន្តអនុវត្តគោលនយោបាយ ផ្សារភ្ជាប់ពាណិជ្ជកម្មទៅនឹងលក្ខខណ្ឌការងារ, ការបណ្តុះបណ្តាលវិជ្ជាជីវៈឲ្យសមស្របតាមសេចក្តីត្រូវការទីផ្សារ, ការផ្សព្វផ្សាយព័ត៌មានអំពីសេចក្តីត្រូវការនៃទីផ្សារការងារ, ការកសាងប្រព័ន្ធស្ថិតិការងារ និងក្របខណ្ឌគុណវុឌ្ឍិជាតិ, ការពង្រឹងយន្តការដោះស្រាយវិវាទការងារ និងការបន្តអនុវត្តច្បាប់ស្តីពីការងារ។

រាជរដ្ឋាភិបាលនីតិកាលទី៥ នឹងបន្តកែទម្រង់ឲ្យបានស៊ីជម្រៅថែមទៀត ទាំងលើគោលនយោបាយ, ក្របខណ្ឌគតិយុត្ត និងយន្តការស្ថាប័នដែលបានអនុវត្តកន្លងមក សំដៅធ្វើឲ្យគ្រប់សមាសភាគនៃទីផ្សារការងារដំណើរការប្រកបដោយភាពស៊ីសង្វាក់គ្នា និងជួយគាំទ្រគ្នាទៅវិញទៅមក ដើម្បីរួមចំណែកលើកកម្ពស់កំណើនសេដ្ឋកិច្ច, បង្កើតការងារ និងលើកស្ទួយជីវភាពប្រជាជន។

- **មុំទី៤. ការអភិវឌ្ឍន៍វិស័យធនាគារ និងហិរញ្ញវត្ថុ**

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺការអភិវឌ្ឍន៍វិស័យធនាគារនិងហិរញ្ញវត្ថុឲ្យមានភាពរឹងមាំ និងផ្អែកលើគោលការណ៍ទីផ្សារសំដៅពង្រឹងតួនាទីជាកម្លាំងចលករនៃវិស័យហិរញ្ញវត្ថុ

ក្នុងការអភិវឌ្ឍន៍ និងពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច ពិសេសតាមរយៈការកៀរគរធនធានហិរញ្ញវត្ថុ ដើម្បីបម្រើឲ្យសេចក្តីត្រូវការហិរញ្ញប្បទានដែលកើនឡើងជាប្រចាំ។

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៥ គឺការបន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុមួយដែលមានវិសាលភាពកាន់តែទូលាយ, កាន់តែមានពិពិធភាព, កាន់តែស៊ីជម្រៅហើយរឹងមាំ និងមានប្រសិទ្ធភាព ដោយផ្អែកលើគោលការណ៍ទីផ្សារ ដើម្បីទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព និងចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញអនុវត្តឲ្យមានប្រសិទ្ធភាពនិងប្រកបដោយផ្លែផ្កានូវ « **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**»។

### ចតុកោណទី៤. ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្ស

- **មុំទី១. ការពង្រឹង និងការលើកកម្ពស់វិស័យអប់រំ, វិទ្យាសាស្ត្រ, បច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស**

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺបន្តអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដោយផ្តោតលើការផ្តល់ឱកាសស្មើៗគ្នាដល់កុមារ និងយុវជនកម្ពុជាទាំងអស់ ក្នុងការទទួលការអប់រំមូលដ្ឋាន, ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ, ព្រមទាំងបន្តយកចិត្តទុកដាក់លើការកែលម្អគុណភាពអប់រំ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការអភិវឌ្ឍន៍ប្រទេស។

រាជរដ្ឋាភិបាលនីតិកាលទី៥ នឹងបន្តជំរុញអនុវត្តគោលការណ៍»**ការអប់រំសម្រាប់ទាំងអស់គ្នា**» សំដៅជានាសមធម៌ ក្នុងការទទួលបានសេវាអប់រំ, បន្តលើកកម្ពស់គុណធម៌ និងប្រសិទ្ធភាពសេវាអប់រំគ្រប់កម្រិត ព្រមទាំងបន្តអភិវឌ្ឍស្ថាប័ន និងសមត្ថភាពមន្ត្រីអប់រំ។

- **មុំទី២. ការលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ**

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺការបន្តអនុវត្ត «ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល» សំដៅលើកកម្ពស់សុខុមាលភាព និងអាហារូបត្ថម្ភរបស់ប្រជាជនទូទៅ, កាត់បន្ថយអត្រាស្លាប់របស់ម្តាយ ទារក និងកុមារ តាមរយៈការពង្រឹង និងពង្រីកសេវាសុខាភិបាលប្រកបដោយគុណភាព, ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

រាជរដ្ឋាភិបាលនីតិកាលទី៥ បន្តជំរុញអនុវត្ត និងធ្វើបច្ចុប្បន្នកម្ម « **ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ២០០៨-២០១៥**» **ដើម្បី**លើកកម្ពស់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃវិស័យសុខាភិបាល សំដៅលើកស្ទួយអនាម័យ, សុខភាព, សុខុមាលភាព និងអាហារូបត្ថម្ភរបស់ប្រជាជនកម្ពុជាឲ្យកាន់តែល្អប្រសើរឡើង ពិសេសសម្រាប់ប្រជាជនក្រីក្រ, ងាយរងគ្រោះ, ស្ត្រី និងកុមារ។

- **មុំទី៣. ការអភិវឌ្ឍន៍ប្រព័ន្ធគាំពារសង្គម**

Draft

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺពង្រឹងប្រព័ន្ធគាំពារសង្គម និងបង្កើតឲ្យមានប្រព័ន្ធគាំពារសង្គមផ្លូវការមួយ សំដៅគាំពារជនក្រីក្រ និងជនងាយរងគ្រោះ ដែលមិនអាចជួយខ្លួនឯងបាន ដើម្បីទប់ទល់នឹងបញ្ហាសុខភាព, អប់រំ, អសន្តិសុខស្បៀង និងផលប៉ះពាល់នៃវិបត្តិនានា។

រាជរដ្ឋាភិបាលនីតិកាលទី៥ នឹងបន្តពង្រឹងប្រព័ន្ធគាំពារសង្គមឲ្យកាន់តែមានភាពប្រទាក់ក្រឡាជាប្រព័ន្ធប្រមូលផ្តុំ, មានសង្គតិភាព និងមានប្រសិទ្ធភាពគ្របដណ្តប់ទាំងវិស័យសាធារណៈ ទាំងវិស័យឯកជន ដែលមានការបែងចែកតួនាទីច្បាស់លាស់ និងកម្រិតនីមួយៗ ពោលគឺកម្រិតគោលនយោបាយ, កម្រិតបញ្ញត្តិករ និងប្រតិបត្តិករ។

- **មុំទី៤. ការជំរុញអនុវត្តគោលនយោបាយជាតិប្រជាជន និងសមភាពយេនឌ័រ**

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៤ គឺការពង្រឹងគុណភាពប្រជាជន, លើកស្ទួយស្ថានភាពស្ត្រី ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ និងប្រែក្លាយយុវជនឲ្យទៅជាកម្លាំងចលករដ៏មានសារៈសំខាន់សម្រាប់ការអភិវឌ្ឍន៍លើគ្រប់វិស័យ។

រាជរដ្ឋាភិបាលនីតិកាលទី៥នឹងផ្តោតការយកចិត្តទុកដាក់ទៅលើការបន្តពង្រឹងការគ្រប់គ្រងជីវភាពប្រជាសាស្ត្រ សំដៅធានាបង្កើនគុណភាព «**មូលធនមនុស្ស**» ដើម្បីទាញយកផលប្រយោជន៍ និងប្រើប្រាស់ឲ្យអស់លទ្ធភាពនូវសក្តានុពលប្រជាសាស្ត្ររបស់កម្ពុជា សម្រាប់ធានាចីរភាពនៃកំណើនសេដ្ឋកិច្ច ព្រមទាំងវឌ្ឍនភាព និងវិបុលភាពរបស់ប្រជាជន។

## ៣.១៨ គោលនយោបាយដីធ្លី

**២៩.** ចក្ខុវិស័យនៃគោលនយោបាយដីធ្លីនៅកម្ពុជាគឺ «គ្រប់គ្រង រៀបចំ ប្រើប្រាស់ និងបែងចែកដីប្រកបដោយសមធម៌ តម្លាភាព ប្រសិទ្ធភាព និងចីរភាព ដើម្បីរួមចំណែកធ្វើឲ្យសម្រេចគោលដៅជាតិនៃការកាត់បន្ថយភាពក្រីក្រ ការធានាសន្តិសុខស្បៀង ការការពារបរិស្ថាន និងធនធានធម្មជាតិ កិច្ចការពារជាតិ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងបរិបទសេដ្ឋកិច្ចទីផ្សារ។«

គោលបំណង និងសកម្មភាពពាក់ព័ន្ធនឹងអនុវិស័យដីធ្លីទាំងបីរួមមាន៖

### ក. អនុវិស័យរដ្ឋបាលដីធ្លី៖

គោលបំណងនៃរដ្ឋបាលដីធ្លី គឺធ្វើការចុះបញ្ជីកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុទាំងអស់ (រដ្ឋ និងឯកជន) ឲ្យបានច្បាស់លាស់ ធ្វើការផ្ទេរសិទ្ធិលើទ្រព្យទាំងនោះជាផ្លូវការ ទប់ស្កាត់ និងដោះស្រាយវិវាទដីធ្លី សំដៅពង្រឹងសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ធានាបាននូវទំនុកទុកចិត្ត និងប្រសិទ្ធភាពនៃទីផ្សារដីធ្លី។

<u>សកម្មភាពនៃអនុវិស័យរដ្ឋបាលដីធ្លីៈ</u>

១- បង្កើត និងពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យពាក់ព័ន្ធ ដូចជាច្បាប់អស្សាមិករណ៍ (**ការដកហូតកម្មសិទ្ធិ**) ច្បាប់ស្តីពីសិទ្ធិបុព្វក្រៃ (**រដ្ឋមានសិទ្ធិទិញមុនអ្នកដទៃ**) ច្បាប់ស្តីពីដីកសិកម្ម (**ការផ្ទេរដី**) ការបង្រួមក្បាលដី ការបំបែកក្បាលដី ពន្ធលើដីធ្លី ការវាយតម្លៃថ្លៃដី ទីផ្សារដី

ធនាគារដី និងការវាស់វែងដី។ល។ ព្រមទាំងធ្វើវិសោធនកម្មមាត្រាច្បាប់ និងបទដ្ឋានគតិយុត្តមួយចំនួនដែលពាក់ព័ន្ធនឹងច្បាប់ភូមិបាល ច្បាប់សារពើពន្ធ......ស្របតាមការវិវត្តនៃសភាពការណ៍ប្រទេសជាតិ។

២- បង្កើតបញ្ជីសារពើភ័ណ្ឌអចលនវត្ថុ (ដី និងអាគារ) របស់រដ្ឋជាជំហានឲ្យបានច្បាស់លាស់ និងពេញលេញនៅក្នុងប្រព័ន្ធទិន្នន័យឯកភាពមួយ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងអចលនវត្ថុរបស់រដ្ឋ។

៣- ដំណើរការចុះបញ្ជីដីធ្លីទូទាំងប្រទេសប្រកបដោយតម្លាភាព និងប្រសិទ្ធភាពសម្រាប់អចលនវត្ថុទាំងអស់ ទាំងដីរដ្ឋ (ដីសាធារណៈ និងឯកជនរបស់រដ្ឋ) និងដីឯកជនរបស់បុគ្គលឯកជន។

៤- បង្កើតប្រព័ន្ធព័ត៌មានធរណីសាស្ត្រ និងធ្វើចំណាត់ថ្នាក់ប្រភេទដី តាមលក្ខណៈពីធម្មជាតិនៃដី។

៥- ការបង្កើតប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ឲ្យមានការឯកភាពនៅទូទាំងប្រទេស។

៦- រៀបចំប្រព័ន្ធវាយតម្លៃថ្លៃដីដែលមានលក្ខណៈចូលរួម តម្លាភាព និងទទួលស្គាល់ជាផ្លូវការ។ ការវាយតម្លៃថ្លៃដី ត្រូវផ្អែកលើគុណភាពអំណោយផលពីធម្មជាតិនៃដី និងរាប់បញ្ចូលអចលនវត្ថុនៅលើដីផងដែរ ដើម្បីបង្កើតជាមូលដ្ឋានមួយសម្រាប់ការលក់- ទិញ ការជួល ការវិនិយោគ ការឲ្យខ្ចីប្រាក់ ការយកពន្ធ (ពន្ធប្រចាំឆ្នាំ ពន្ធលើការផ្ទេរ លើការជួល លើប្រាក់ចំណេញ លើដីធ្លីមិនប្រើប្រាស់) ការកំណត់សេវាសុរិយោដី និងការទូទាត់សំណង..។ល។

៧- លើកទឹកចិត្តឲ្យមានការចូលរួមពីវិស័យឯកជនលើការងារវាស់វែងដីធ្លី ក្រោមការត្រួតពិនិត្យរបស់រដ្ឋបាលសុរិយោដី។

៨- បន្តដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការតាមរយៈគណៈកម្មការរដ្ឋបាល គណៈកម្មការសុរិយោដីគ្រប់លំដាប់ថ្នាក់ (ថ្នាក់ជាតិ ថ្នាក់រាជធានី-ខេត្ត ថ្នាក់ក្រុង-ស្រុក-ខណ្ឌ និងក្រុមចល័ត) និងអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី ជាពិសេសចំពោះករណីវិវាទពហុភាគី។

៩- បង្កើតប្រព័ន្ធស្វ័យគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ផ្នែករដ្ឋបាលដីធ្លី ដោយផ្តើមចេញពីចំណូលបានមកពីការចុះបញ្ជី និងពីសេវាសុរិយោដីដើម្បីគាំទ្រ និងពន្លឿនដំណើរការចុះបញ្ជីដីនៅទូទាំងប្រទេស។

**ខ. អនុវិស័យរៀបចំដែនដី**

គោលបំណងនៃការរៀបចំដែនដី គឺធានាការគ្រប់គ្រង ការការពារ និងការប្រើប្រាស់ដី និងធនធានធម្មជាតិប្រកបដោយតម្លាភាព និងប្រសិទ្ធភាព ដើម្បីរក្សានិរន្តរភាពបរិស្ថាន និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រកបដោយសមធម៌នៅទីប្រជុំជន និងជនបទ ព្រមទាំងទប់ស្កាត់វិវាទលើការប្រើប្រាស់ដី ដោយដាក់បញ្ញត្តិលើការអភិវឌ្ឍន៍ដី ការប្តូរប្រភេទនៃការប្រើប្រាស់ដី លើការកែសម្រួលក្បាលដី លើការសាងសង់ លើការតាំងទីលំនៅជាថ្មី អនុលោមតាមច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ក្របខណ្ឌយុទ្ធសាស្ត្រគោលនយោបាយដីធ្លី គោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងអភិបាលកិច្ចល្អ។

ទន្ទឹមនេះ ការងាររៀបចំដែនដីត្រូវធ្វើឲ្យស្របតាមគោលការណ៍សមធម៌ តម្លាភាព ការចូលរួម ការព្រមព្រៀងគ្នា និងការគោរពតាមឋានានុក្រមនៃការរៀបចំផែនការ បទបញ្ញានិងនីតិវិធីពាក់ព័ន្ធ។

Draft

## សកម្មភាពនៃអនុវិស័យរៀបចំដែនដី

១- អភិវឌ្ឍគោលនយោបាយជាតិ និងក្របខ័ណ្ឌគតិយុត្ត ព្រមទាំងនីតិវិធីសមស្របសម្រាប់ការគ្រប់គ្រង អភិវឌ្ឍដីនៅទីប្រជុំជន និងជនបទ រួមទាំងដីបម្រើឲ្យផលិតកម្មកសិកម្ម ការសាងសង់ និងការតាំងទីលំនៅជាថ្មី។

២- បង្កើតប្រព័ន្ធផែនការរៀបចំដែនដី ដែលចង្អុលបង្ហាញអំពីការរៀបចំតំបន់ ឬទីតាំងនីមួយៗ ដោយផ្អែកលើលក្ខណៈពីធម្មជាតិនៃដី និងតម្រូវការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រកបដោយសមធម៌។

៣- រាល់ផែនការប្រើប្រាស់ដីសម្រាប់តំបន់អាទិភាពដូចជា ផែនការអភិវឌ្ឍន៍តំបន់ឆ្នេរ តំបន់ទេសចរណ៍ តំបន់វិនិយោគ តំបន់ដែលមានសក្តានុពលសេដ្ឋកិច្ច តំបន់ទីប្រជុំជន និងច្រករបៀងសំខាន់ៗ ត្រូវគោរពតាមគោលការណ៍ តម្លាភាព ការចូលរួម ការព្រមព្រៀងគ្នា សមធម៌ និងជានានិរន្តរភាព។

៤- គ្រប់គ្រង និងត្រួតពិនិត្យការប្រើប្រាស់ដី និងធនធានធម្មជាតិ។

៥- ជំរុញការធ្វើផែនការរៀបចំដែនដីថ្នាក់ជាតិ ថ្នាក់ខេត្ត និងផែនការប្រើប្រាស់ដីថ្នាក់ក្រោមជាតិ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ។

៦- ពន្លឿនការរៀបចំគោលការណ៍ណែនាំលើការប្រើប្រាស់ដីនៅមូលដ្ឋាន ដើម្បីគាំទ្រដល់វិមជ្ឈការ និងសហវិមជ្ឈការនៃការរៀបចំដែនដីក្រោមការគាំទ្របច្ចេកទេសពីថ្នាក់ជាតិដល់អាជ្ញាធរមូលដ្ឋាន។

៧- ជំរុញវិមជ្ឈការនៃការរៀបចំដែនដី។ ស្ថាប័នដែលមានអាណត្តិកាន់កាប់ដីរដ្ឋ ត្រូវផ្តល់បញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីឲ្យក្រសួងនេះធ្វើរបាយការណ៍សរុបជូនរាជរដ្ឋាភិបាល អំពីស្ថានភាពនៃការប្រើប្រាស់ដី។ សាធារណៈជនអាចទទួលបានព័ត៌មាននេះពីស្ថាប័នពាក់ព័ន្ធ។ ស្ថាប័នដែលទទួលបានអាណត្តិកាន់កាប់ដីរដ្ឋ រួមជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវទទួលខុសត្រូវក្នុងការពារ និងជានានូវគណនេយ្យភាពចំពោះការគ្រប់គ្រងដីសាធារណៈ និងដីឯកជនរបស់រដ្ឋ។

### គ- អនុវិស័យបែងចែកដីធ្លី

គោលបំណងនៃការបែងចែកដីធ្លី គឺផ្តល់ទិសដៅច្បាស់លាស់ដើម្បីធ្វើការបែងចែក និងការប្រើប្រាស់ដីរដ្ឋសម្រាប់គោលបំណងឯកជន និងសាធារណៈ ប្រកបដោយតម្លាភាព និងសមធម៌ដោយឆ្លើយតបទៅនឹងតម្រូវការដីរបស់ប្រជាពលរដ្ឋទូទៅ ជាពិសេសប្រជាពលរដ្ឋក្រីក្រ យុទ្ធជនពិការ និងគ្រួសារយុទ្ធជនពលី ដែលគ្មានដី និងខ្វះដីតាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ច។

ការបែងចែកដីធ្លី ត្រូវធានាឲ្យបាននូវសមធម៌ ស្ថិរភាពសង្គម សន្តិសុខស្បៀង និងការសម្រួលដល់ការវិនិយោគ ដោយផ្អែកលើប្រភេទ និងគុណភាពអំណោយផលពីធម្មជាតិនៃដី ដើម្បីការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព ទប់ស្កាត់ការប្រមូលដីទុក នឹងជំរុញការប្រើប្រាស់ដីប្រកបដោយប្រសិទ្ធភាព និងផលិតភាព។

Draft

**<u>សកម្មភាពនៃការបែងចែកដីធ្លី៖</u>**

១- ជំរុញការប្រមូល និងចងក្រងបញ្ជីសារពើភ័ណ្ឌដីរដ្ឋ សម្រាប់បម្រុងទុកក្នុងគោលដៅបែងចែក និងប្រើប្រាស់ដីពេលបច្ចុប្បន្ន និងទៅអនាគតប្រកបដោយសមធម៌ តម្លាភាព និងគណនេយ្យភាព។

២- បង្កើត និងអនុវត្តយុទ្ធសាស្ត្រ និងក្របខណ្ឌនៃផែនការបែងចែកដីធ្លីរយៈពេលមធ្យម និងវែង ដើម្បីបែងចែក និងប្រើប្រាស់ដីសម្រាប់គោលដៅសង្គមកិច្ច និងសេដ្ឋកិច្ច ស្របតាមផែនការថ្នាក់ជាតិ ថ្នាក់រាជធានី-ខេត្ត ថ្នាក់ក្រុង-ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ ដោយធានាតម្លាភាព និងប្រសិទ្ធភាព ចៀសវាងការជះឥទ្ធិពលអវិជ្ជមានដល់សង្គម និងបរិស្ថាន។

៣- ជំរុញការបែងចែកដីធ្លីសម្រាប់គោលដៅសង្គមកិច្ចឲ្យបានទាន់ពេលវេលាដើម្បីរួមចំណែកដោះស្រាយបញ្ហាសង្គម និងទប់ស្កាត់ការទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់។

៤- អនុវត្តភាពជាដៃគូរវាងម្ចាស់ចម្ការខ្នាតតូច ខ្នាតធំ និងសាជីវកម្មនៅក្នុងការងារកសិផលិតកម្ម និងរវាងសម្បទានដីសេដ្ឋកិច្ច សំដៅបង្កើតការងារធ្វើ និងបង្កើតទីផ្សារ សម្រាប់អ្នករស់នៅក្នុងមូលដ្ឋាន។

Draft

### ៣-១៩ បទបញ្ជា ស្តីពីវិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច

៣០. អនុលោមតាមគោលនយោបាយស្តីពីការពង្រឹងប្រព័ន្ធគ្រប់គ្រងបែងចែកនិងប្រើប្រាស់ដីធ្លី ជាពិសេសដោយពិនិត្យឃើញតម្រូវការចាំបាច់ និងបន្ទាន់ចំពោះមុខក្នុងការធានាសមធម៌ ពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវបទបញ្ជាឲ្យក្រសួង ស្ថាប័ន និងអាជ្ញាធរដែលមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីអនុវត្តដូចខាងក្រោម៖

១- ផ្អាកជាបណ្តោះអាសន្ននូវការផ្តល់សម្បទានដីសេដ្ឋកិច្ច។

២- ក្រសួង ស្ថាប័ន និងអាជ្ញាធរដែលមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់នូវគោលនយោបាយ និងរាល់លក្ខខណ្ឌទាំងឡាយនៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការផ្តល់ដីសម្បទានសេដ្ឋកិច្ច និងផ្តោតការយកចិត្តទុកដាក់លើការអនុវត្តកិច្ចសន្យាស្តីពីសម្បទានដីសេដ្ឋកិច្ច ពិសេសការអនុវត្តតាមគោលនយោបាយរូបមន្តស្បែកខ្លា និងមិនធ្វើឲ្យប៉ះពាល់ដល់ដីធ្លីសហគមន៍ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងគោលដៅធ្វើឲ្យសម្បទានដីសេដ្ឋកិច្ចទាំងអស់នេះបានផ្តល់ផលប្រយោជន៍ពិតប្រាកដជូនដល់ប្រទេសជាតិ និងប្រជាជនប្រកបដោយចីរភាព។

៣- ចំពោះក្រុមហ៊ុនដែលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលរួចហើយ តែមិនទាន់បានអនុវត្តតាមនីតិវិធីច្បាប់ជាធរមាន និងតាមកិច្ចសន្យា ដោយកាប់ឈើលក់ហើយមិនធ្វើការអភិវឌ្ឍន៍ដីសម្បទាន ទន្ទ្រានដីបន្ថែម ទុកដីចោលទំនេរសម្រាប់លក់បន្ត ធ្វើអាជីវកម្មខុសលក្ខខណ្ឌនៃកិច្ចសន្យា បំពានដីប្រជាពលរដ្ឋ ឬដីសហគមន៍ រាជរដ្ឋាភិបាលនឹងដកហូតនូវដីសម្បទានសេដ្ឋកិច្ចទាំងនោះមកវិញ។ ដីសម្បទានសេដ្ឋកិច្ចដែលត្រូវបានដកហូតមកវិញនោះ នឹងត្រូវដាក់ឲ្យនៅក្រោមការគ្រប់គ្រងរបស់រដ្ឋដោយផ្ទាល់។

៤- ចំពោះសម្បទានដីសេដ្ឋកិច្ចដែលបានទទួលការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាលរួចហើយ មុនថ្ងៃចេញបទបញ្ជានេះ ត្រូវអនុវត្តតាមគោលការណ៍ច្បាប់និងនីតិវិធីជាធរមាន។